CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៧ | ថ្ងៃទី០១- ៣១ ខែ ធ្នូ ឆ្នាំ២០១៤ លក់តម្លៃ ១០០០រៀល | លេខ ៨២



## ព្រះសហគមន៍មានគង្វាលថ្មីពីររូបបន្ថែមទៀត

---

## សេចក្តីជូនដំណឹង

គណៈកម្មការសម្រាប់កិច្ចការមរណសាក្សីនៅកម្ពុជា សូមជម្រាបដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់ឲ្យបានជ្រាបថា បច្ចុប្បន្នគណៈកម្មការយើងខ្ញុំកំពុងធ្វើ និង ចងក្រងសំណុំឯកសារអំពីមរណសាក្សីនៃព្រះសហគមន៍កាតូលិក។ សូមបងប្អូនសហការផ្តល់ជាព័ត៌មានមកកាន់ ៖ លោករឿង ឆ័ត្រ សិរី (Fr. RoeungChatsirey )។ Tel: ០៧៧ ៨០០ ២១១ និង ០៩៦ ៣៤ ២២ ១៤៤

អ៊ីម៉ែល ៖ martyrscambodia@gmail.com | ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

# រូបភាពពីព្រះសហគមន៍កាតូលិក



លោក មួង រស់ ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅបាត់ដំបង



លោក ផាន បូរី ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅកំពង់ចាម


## កម្មវិធីអភិវឌ្ឍន៍យុវជននៃអង្គការការីតាសកម្ពុជា

Caritas CAMBODIA

សូមប្រកាសជ្រើសរើសយុវជនក្រីក្រមកពីគ្រប់ខេត្ត រាជធានី នៅក្នុងប្រទេសកម្ពុជាដែលពុំមានលទ្ធភាពបន្តការសិក្សាចំនួន១១០នាក់ឲ្យចូលរៀនក្នុងឆ្នាំសិក្សាថ្មីនេះដោយឥតបង់ថ្លៃលើជំនាញវិជ្ជាជីវៈដូចខាងក្រោម៖

១. អ៊ុតសក់និងកែសម្ផស្ស
២. ជួសជុលរថយន្តនិងជួសជុលម៉ូតូ
៣. ជួសជុលអេឡិចត្រូនិច និងជួសជុលទូរស័ព្ទ
៤. អគ្គិសនី
៥. គ្រប់គ្រងភោជនីយដ្ឋាន
៦. ជួសជុលម៉ាស៊ីនត្រជាក់
៧. ជួសជុលម៉ាស៊ីនដេរ
៨. គំនូរ និង ចលនា3D
៩. វិទ្យាសាស្ត្រកុំព្យូទ័រ
១០. រដ្ឋបាលនិងមូលដ្ឋានគ្រឹះគណនេយ្យ
១១. អភិវឌ្ឍន៍សហគមន៍និងគ្រឿងយន្តកសិកម្ម

**ចាប់ផ្តើមទទួលពាក្យសិក្សារាល់ម៉ោងធ្វើការ ចាប់ពីការផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី១៨ ខែមករា ២០១៨**

**ព័ត៌មានបន្ថែមទូរស័ព្ទលេខ៖**
**០១៧ ៨៧៤២៣២ / ០២៤៦៥០៩៦៥៤**



Radio Veritas Asia — Crossing Borders, Sharing Christ

**វិទ្យុវេរីតាស់អាស៊ី (RVA) ផ្សាយតាមរលកធាតុអាកាសខ្លី (SW) ភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃ :**

ពីម៉ោង៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវេរីតាស់អាស៊ី (RVA) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើនទាក់ទងនឹង ជីវិតរស់នៅប្រចាំថ្ងៃ សង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកកម្ពុជា។



**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

**Tel/Fax** : (855) 23 224 120

**Email** : csccambodia@gmail.com / **Website** : www.catholiccambodia.org

**ចាងហ្វាង : លោក លី សុវណ្ណា**

Licence ៣៧០ ពម.ប្រក./ ២៤-មិថុនា-២០១០

## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

## រដូវអបអរសាទរព្រះគ្រីស្តយាងមក ឆ្នាំ២០១៤

## ឆ្នាំមេត្តាករុណា

បងប្អូនជាទីស្រឡាញ់ !

*"សូមព្រះជាម្ចាស់ជាព្រះបិតា និង ព្រះអម្ចាស់យេស៊ូគ្រីស្តប្រណីសន្តោស និង ប្រទានសេចក្តីសុខសាន្តដល់បងប្អូន" ( ១ករ ១,៣ ) ។ អត្ថបទទី ២ នៅថ្ងៃអាទិត្យទី ១ )*

ក្នុងរដូវអបអរសាទរព្រះគ្រីស្តយាងមក ព្រះសហគមន៍សូមឲ្យយើងធ្វើដំណើរអស់រយៈបួនអាទិត្យ ដើម្បីទទួលព្រះយេស៊ូដែលយាងមក គឺព្រះអង្គដែលប្រសូត្រក្នុងពិភពលោកនេះ និង ក្នុងចិត្តយើង ។

"យើងខ្ញុំទាំងអស់គ្នាប្រៀបបាននឹងដីឥដ្ឋ ហើយព្រះអង្គដូចជាជាងស្មូន ។ យើងខ្ញុំទាំងអស់គ្នា សុទ្ធតែជាស្នាព្រះហស្តរបស់ព្រះអង្គ" ( អស ៦៤,៧ ។ អត្ថបទទី ១ នៅថ្ងៃអាទិត្យទី១ ) ។

រដូវអបអរសាទរព្រះគ្រីស្តយាងមកហុចឱកាសឲ្យយើងម្នាក់ៗ អង្គុយរិះគិតអំពីការរស់នៅរបស់ខ្លួនតាមពន្លឺនៃដំណឹងល្អ ដើម្បីបណ្តោយខ្លួនឲ្យព្រះបិតាសូនពូនចិត្តគំនិតរបស់យើង ។

បងប្អូនជាទីស្រឡាញ់ !

ខ្ញុំសូមអញ្ជើញបងប្អូនឲ្យរកពេលវេលាក្នុងអាទិត្យទាំងបួនខាងមុខនេះ ដើម្បី ៖

១- ឲ្យប្រែជាថ្មី ៖ "ចូរប្រុងស្មារតី កុំដេកលក់ឲ្យសោះ !" ( គម្ពីរដំណឹងល្អតាមសន្តម៉ាកុស ថ្ងៃអាទិត្យទី ១ )

- ចូរប្រុងស្មារតី មិនគ្រាន់មិនដេកលក់ប៉ុណ្ណោះទេ តែត្រូវបើកភ្នែកចំហ សម្លឹងមើលការរស់នៅរបស់ខ្លួន សម្លឹងមើលសហគមន៍គ្រីស្តបរិស័ទយើង និងសម្លឹងមើលពិភពលោកយើង ។
- រដូវអបអរសាទរព្រះគ្រីស្តដែលមក ពិតជាហុចឱកាសឲ្យយើងប្រែជីវិតផ្ទាល់ខ្លួនឲ្យបានជាថ្មី ឲ្យសហគមន៍យើងប្រែជាថ្មី ។ "យើងម្នាក់ៗត្រូវតែសួរថា ក្នុងការរស់នៅរបស់ខ្ញុំ តើខ្ញុំត្រូវប្រែអ្វីខ្លះ ? "

២- រដូវអបអរសាទរព្រះគ្រីស្តយាងមក ពិតជាពេលអង្វរព្រះជាម្ចាស់ សូមឲ្យសន្តិភាពកើតឡើង ។ "ខ្ញុំត្រងត្រាប់ស្តាប់សេចក្តីដែលព្រះជាអម្ចាស់មានព្រះបន្ទូល ។ ព្រះអង្គមានព្រះបន្ទូលថា នឹងប្រទានសេចក្តីសុខសាន្ត ដល់ប្រជារាស្ត្រ និង ដល់អស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ" ( ទន ៨៦,៩ ។ ថ្ងៃអាទិត្យទី ២ )

- ព្រះកុមារយេស៊ូដែលយើងរៀបចំខ្លួននឹងទទួលនោះ ជាព្រះអម្ចាស់នៃសេចក្តីសុខសាន្ត ។
- ប៉ុន្តែសេចក្តីសុខសាន្ត មិនទាន់មាននៅជុំវិញយើងនៅឡើយទេ គឺមិនទាន់មានសេចក្តីសុខសាន្តក្នុងចិត្ត សេចក្តីសុខសាន្តក្នុងក្រុមគ្រួសារ សេចក្តីសុខសាន្តក្នុងការងារ ឲ្យស្ថិតស្ថេរ ឲ្យមានអាហារគ្រប់គ្រាន់អាចសិក្សាបាន ។ល។ យើងម្នាក់ៗ ត្រូវតែសួរសំណួរដល់ខ្លួនឯងថា ៖ " តើខ្ញុំអាចនាំសារស្តីអំពីសេចក្តីសុខសាន្តរបស់ព្រះយេស៊ូដល់អ្នកដទៃដូចម្តេចបាន ?"



៣-រដូវអបអរសាទរព្រះគ្រីស្តដែលយាងមក ជាពេលវេលាសម្តែងសេចក្តីអំណរ ។ "ខ្ញុំមានអំណរយ៉ាងខ្លាំង ព្រោះតែព្រះអម្ចាស់ ខ្ញុំរីករាយយ៉ាងខ្លាំងអស់ពីចិត្ត ព្រោះតែព្រះរបស់ខ្ញុំ " ( អស ៦១,១០ ។ ថ្ងៃអាទិត្យទី ៣ )

- យើងមានអំណរយ៉ាងខ្លាំង ដោយរៀបចំចិត្តគំនិតទទួលព្រះយេស៊ូ ។
- តើសង្គមខ្មែរយើង រៀបចំទទួលព្រះយេស៊ូយ៉ាងដូចម្តេច ? មានដាក់ដើមស្រល់ក្នុងហាងធំៗ មានតុបតែងផ្លូវក្នុងទីក្រុង ។ អ្វីជាអំណរក្នុងការទទួលព្រះយេស៊ូ ? យើងត្រូវតែសួរខ្លួនឯងថា តើខ្ញុំអាចចែកអំណររបស់ខ្ញុំដែលព្រះយេស៊ូយាងមក ដល់អ្នកដទៃបានយ៉ាងដូចម្តេច ?

៤- រដូវអបអរសាទរព្រះគ្រីស្តដែលយាងមក ជាពេលវេលាសម្រាប់អរព្រះគុណទាំងមានចិត្តស្រឡាញ់ ។ "ខ្ញុំនឹងច្រៀងសរសើរព្រះហឫទ័យ មេត្តាករុណារបស់ព្រះអម្ចាស់រហូតតទៅ ។ ខ្ញុំសូមប្រកាសថា ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេរអស់កល្បជានិច្ច" ( ថ្ងៃអាទិត្យ ទី ៤ ។ ទន ៨៩,២ ) ។

- បុណ្យលើកតម្កើងព្រះយេស៊ូប្រសូត្រ ជាឱកាសចែកចាយអ្វីៗដែលខ្លួនមានដល់អ្នកដទៃ ហើយមិនគ្រាន់តែកាដូប៉ុណ្ណោះទេ តែចែកចាយជាពិសេសនូវសេចក្តីសង្ឃឹម និង សេចក្តីស្រឡាញ់ ដែលព្រះបិតាបានចាក់បង្ហូរក្នុងចិត្តរបស់យើង ។
- តើក្នុងឆ្នាំមេត្តាករុណានេះយើងនឹងធ្វើអ្វីខ្លះសម្រាប់អ្នកដទៃ ? តើយើងចែកសញ្ញាសម្គាល់ដ៏តូចតាចណាខ្លះចំពោះគេ ? យើងត្រូវតែសួរខ្លួនឯងថា តើខ្ញុំស្រឡាញ់អ្នកដទៃដោយយកព្រះយេស៊ូជាអ្នកបម្រើ និង ជាគ្រូពេទ្យនៃចិត្តគំនិតបម្រើមនុស្សលោកធ្វើជាគំរូយ៉ាងណា ?

បងប្អូនជាទីស្រឡាញ់ !

សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូន និង ប្រោសប្រណីឲ្យបងប្អូនរស់នៅដោយសេចក្តីសុខសាន្តក្នុងរដូវដ៏ប្រសើររៀបចំបុណ្យព្រះយេស៊ូប្រសូតនេះ ។



អូលីវីយេ ផ្មិតហាស្លេរ

ជាអភិបាលរបស់បងប្អូន

## អ្នកភ្នំពេញត្រូវការផ្ទះថ្មី ជាង២០ម៉ឺនខ្នងក្នុងមួយឆ្នាំ

រាជធានីភ្នំពេញ ដែលជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម និង វប្បធម៌របស់ប្រទេសកម្ពុជា ត្រូវការលំនៅដ្ឋានថ្មី ប្រមាណជាជាង ២០ម៉ឺនផ្ទះ នៅក្នុងរយៈពេលមួយឆ្នាំៗ ។

លោក ប៉ា សុជាតិវង្ស អភិបាលរាជធានីភ្នំពេញ បានមានប្រសាសន៍នៅក្នុងពេលចូលរួម ពិធីតាំងពិព័រណ៍ឧស្សាហកម្មសំណង់ និង មហាសន្និបាត បូកសរុបការងារលើកទី៣ របស់សមាគមអ្នកសាងសង់កម្ពុជាដែលបានបើកនៅមជ្ឈមណ្ឌលសន្និបាត និង ពិព័រណ៍ កោះពេជ្រ កាលពីថ្ងៃទី០៣ ខែធ្នូកន្លងទៅថា នេះគឺជាតំរូវការលំនៅដ្ឋានរបស់ប្រជាពលរដ្ឋប្រចាំឆ្នាំ ។

លោកបានមានប្រសាសន៍ ឲ្យដឹងថា រាជធានីភ្នំពេញ បច្ចុប្បន្ននេះត្រូវបានពង្រីកផ្ទៃដី រហូតដល់ជាង៦៧៨គីឡូម៉ែត្រការ៉េ ដែលផ្ទៃដីនេះ ស្មើនឹង ០,៣៧ភាគរយ នៃផ្ទៃដីសរុបទូទាំងប្រទេស។

លោកបានបន្តទៀតថា ដោយឡែក ចំនួនប្រជាជនដែលរស់នៅក្នុងរាជធានីភ្នំពេញ ជាអចិន្ត្រៃយ៍មានប្រមាណជាង ១.៥លាននាក់ ដោយនៅក្នុងនោះ ក្នុងអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ចំនួន ១,៤ ភាគរយ នៃចំនួនប្រជាជនកម្ពុជា សរុបស្មើនឹងជាង ២២ ម៉ឺននាក់ ដូច្នេះតម្រូវការផ្ទះសម្បែងសម្រាប់ការរស់នៅ របស់ប្រជាពលរដ្ឋ អាចប្រហាក់ប្រហែលជាង២០ម៉ឺនផ្ទះក្នុងមួយឆ្នាំៗនៅអនាគត។

គួររំលឹកដែរថាកម្មវិធីតាំងពិព័រណ៍ឧស្សាហកម្មសំណង់ និង មហាសន្និបាតបូកសរុបការងារលើកទី ៣ របស់សមាគមអ្នកសាងសង់កម្ពុជានេះ ត្រូវបានរៀបចំឡើងរយៈពេល ៣ ថ្ងៃ ដោយចាប់ផ្ដើម ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៤ ដោយមានការចូលរួម តាំងពីពិព័រណ៍ពីក្រុមហ៊ុននៅក្នុងស្រុក និង មកពីបរទេសចំនួន២៤០ ស្តង់មានទំនិញជាសំភារៈ និង គ្រឿងសំណង់ ចំនួនប្រមាណជា ២០០ផលិតផល របស់ក្រុមហ៊ុនចំនួន ៩៦ ក្រុមហ៊ុន៕

# តម្លៃទុនវិនិយោគវិស័យសំណង់រយៈពេល៩ខែ ឆ្នាំ២០១៤មានតម្លៃ២,៣០ពាន់លានដុល្លារ




អាគារ៤២ជាន់មិនដំណើរការសាងសង់រយៈពេលជិត៤ឆ្នាំមកហើយតាមបណ្តោយផ្លូវព្រះសីហនុ។ លីហៀង

រាជធានីភ្នំពេញ ៖ នៅក្នុងរយៈពេល ៩ ខែ ដើមឆ្នាំ២០១៤ នេះ គម្រោងវិនិយោគលើវិស័យសំណង់ គឺ មានតម្លៃសរុបប្រមាណជា ២,៣០ ពាន់លានដុល្លារ ។

យោងតាមទិន្នន័យពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ កាលពីពេលថ្មីៗនេះបង្ហាញថា តម្លៃទុនវិនិយោគវិស័យសំណង់ នៅកម្ពុជា នៅរយៈពេល៩ខែ ឆ្នាំ២០១៤ នេះ បន្តកើនឡើង ដោយមានតម្លៃសរុប ប្រមាណជាង ២,៣០ ពាន់លាន ដុល្លារអាមេរិក។

ប្រភពដដែលនោះ បានឲ្យដឹងថា ក្រសួងបានផ្តល់លិខិតអនុញ្ញាតសាងសង់ ដែលមានចំនួន ប្រមាណជា ១,៨ពាន់គម្រោង និង ផ្ទៃក្រឡាសាងសង់សរុបចំនួនជាង ៥ លាន ម៉ែត្រការ៉េ។

វិស័យសំណង់ជាវិស័យស្នូលមួយដែលកំពុងដើរតួនាទីសំខាន់ ក្នុងការជម្រុញកំណើនសេដ្ឋកិច្ច ហើយការកើនឡើងវិស័យសំណង់នាពេលនេះ គឺដោយសារតែកំណើនសេដ្ឋកិច្ចជាតិមានការកើនឡើង ប្រជាពលរដ្ឋមានជីវភាពធូរធារ។

លោក ស៊ុន សេង ប្រជាពលរដ្ឋកម្ពុជាមួយរូបនៅក្នុងខណ្ឌ ៧ មករា បានមានប្រសាសន៍ថា វិស័យសំណង់ គឺពិតជារីកចំរើនមែន ជិះមើលតែតាមផ្លូវនានា នៅក្នុងតំបន់ក្បែរផ្ទះរបស់លោកឃើញថាការដ្ឋានសំណង់គឺមានព្រោងព្រាត ហើយការដ្ឋានទាំងនោះភាគច្រើន គឺជាការដ្ឋានដែលមានអាគារខ្ពស់ៗ ចាប់ពី ១០ ទៅ២០ ជាន់ឡើងលើ ។

ជុំវិញការកើនឡើង នៃសំណង់នេះ លោក សេង បានចូលរួមអបអរ ប៉ុន្តែទន្ទឹមនឹងការអបអរ លោកបានជំរុញឲ្យបណ្តាម្ចាស់គម្រោងសាងសង់ និង ក្រុមហ៊ុនសំណង់ប្រយ័ត្នរឿងស្តង់ដាសុវត្ថិភាព។

លោកបានបញ្ជាក់ថា "បានអានព័ត៌មានអំពីករណីគ្រោះថ្នាក់នៅតាមដងផ្លូវ លើស្ត្រីម្នាក់ នៅជិតការដ្ឋានក្រុមហ៊ុនសាងសង់សំណង់ ជុំវិញ ស្តាតខ្ញុំពិតជាបារម្ភណាស់" ។

នេះគឺជាការលើកឡើង អំពីការព្រួយបារម្ភរបស់ប្រជាពលរដ្ឋមួយរូប ខណៈដែលប្រជាពលរដ្ឋមួយរូបទៀត ដែលជាអ្នកធ្វើដំណើរតាមដងផ្លូវមួយ នៅជិតនឹងការដ្ឋានសាងសង់សំណង់ នៅម្តុំវត្តមហាមន្ត្រីឈ្មោះធក់ សំណាង បានឲ្យដឹងថា គាត់ធុញទ្រាន់នឹងការកកស្ទះចរាចរណ៍ និង កង្វះការទទួលខុសត្រូវ របស់ក្រុមហ៊ុនសំណង់ទាំងនោះ។

លោកបានបញ្ជាក់ថា "ថ្ងៃមុនខ្ញុំជិះកាត់តាមផ្លូវមួយ មិនដឹងជាការដ្ឋាននោះធ្លាក់ស្អីទេ គឺខ្ទាចទឹកស៊ីម៉ង់ប្រឡាក់ ខោ និង អាវខ្ញុំពេញ"។

លោកបានត្អូញត្អែរផងដែរ អំពីការកកស្ទះចរាចរណ៍ផ្សេងៗ ដែលបានកើតមាននៅតាមកន្លែងដែលមានការដ្ឋានសំណង់ទាំងនោះផងដែរ។

លោកបានបញ្ជាក់ថា "ការដ្ឋានទាំងនោះធ្វើសំណង់មិនខ្វល់ថាស្ថានភាពចរាចរណ៍យ៉ាងម៉េចទេ ពេលម៉ោង ៥ទៅ៦ ដែលចរាចរណ៍ណែនពេញទំហឹង ឡានក្រឡុកស៊ីម៉ង់ សំកាំងរាប់សិបគ្រឿងបន្តកន្ទុយគ្នា "។

លោកបានបន្តទៀតថា ការដ្ឋានទាំងនោះ គួរតែធ្វើការចាក់ស៊ីម៉ង់នេះនៅម៉ោងដែលចរាចរណ៍ មិនសូវរវល់ទៅ ហើយសូមប្រយ័ត្នប្រយែងផងរឿងសុវត្ថិភាពដើម្បីជាការគោរពសិទ្ធិអ្នកដទៃ ពិសេសសិទ្ធិអ្នកធ្វើដំណើរ។

ក្រៅពីការរំខានរឿងចរាចរណ៍ បរិយាកាសជុំវិញការដ្ឋាន បញ្ហាបរិស្ថាន ការគោរពស្តង់ដាសុវត្ថិភាព ការរំខានដោយសម្លេង ក៏ជាបញ្ហា ដែលគួរតែក្រុមហ៊ុនសំណង់ យកចិត្តទុកដាក់ផងដែរ៕

**ដោយអរិយបុត្រ**

# យុវជនប្រាប់យុវជនថា ការសម្លាប់ខ្លួននិងអំពើហិង្សាមិនមែនជាដំណោះស្រាយទេ

*យុវជន បានប្រាប់យុវជនថា ជីវិតគឺជាវត្ថុដែលមានតម្លៃ ដែលធម្មជាតិបានផ្តល់មក ហើយសម្រាប់អ្នក ដែលមានជំនឿសាសនាបានអះអាងថា គឺជាវត្ថុ ដែលព្រះជាម្ចាស់ផ្តល់មក ដូច្នេះមនុស្ស ជាពិសេស គឺយុវជនមិនគួរ បញ្ចប់ជីវិតខ្លួនឯង ដោយអំពើអត្តឃាតនោះទេ ។*



វីដេអូរបស់យុវជននៅលើគេហទំព័រហ្វេសបុក (Facebook)មុនពេលធ្វើអត្តឃាត ។រូបថត: លីហៀង

លោក នេត សុភ័ក្រ ជាអ្នកជំនួញខ្នាតតូច វ័យ ២៨ ឆ្នាំមួយរូប បានអះអាងថា "ខ្ញុំចេះតែឆ្ងល់ អំពីមូលហេតុដែលយុវជនគាត់គិតខ្លីដោយសារតែរឿងបន្តិចបន្តួចដាច់ចិត្តយកជីវិតទៅលេងសើច"។ លោកបានបន្តទៀតថា មនុស្សម្នាក់ៗមិនថាវណ្ណៈណាទេ តាំងពីកើតមក ទំរាំដឹងក្តីមិនមែនជារឿងងាយស្រួលទេ ចុះហេតុអ្វីបានជានាំគ្នាចេះតែយកជីវិតទៅបញ្ចប់ងាយៗបែបនេះ ។

លោកបានបន្តទៀតថា ខ្ញុំបានអានកាសែត និង មើលវ៉ើបសាយ ឃើញព័ត៌មានសម្លាប់ខ្លួន ខ្ញុំហួសចិត្តមែនទែន និង សកម្មភាពគិតខ្លីបែបនេះ។ លោកបានបន្តទៀតថា ជីវិតគឺជាការតស៊ូ ហេតុអ្វី បានជាពេលដែលជីវិតជួបការលំបាកបន្តិចបន្តួច នាំគ្នាទៅប្រព្រឹត្តិអំពើផ្តេសផ្តាស បែបនេះទៅកើត។

លោកបានបញ្ជាក់ថា "ខ្ញុំក៏ជាយុវជនមួយរូប ហើយក៏ធ្លាប់មានវិបត្តិស្នេហ៍ និង ខកចិត្តនឹងការងារ ធ្លាប់បរាជ័យនឹងមុខរបរ ជំពាក់គេ ប៉ុន្តែគ្រប់បញ្ហា គឺមិនមែនគ្មានដំណោះស្រាយនោះទេ ដូច្នេះសូមកុំនាំគ្នាគិតខ្លី"។

សុភ័ក្រ បានឲ្យដឹងថា រូបគេក៏ជាយុវជន ដែលធ្លាប់ខូចចិត្តមួយរូបដែរ ដោយសារតែវិបត្តិស្នេហ៍នេះ ជាពិសេស គឺ នៅពេលដែលរូបគេរៀននៅមហាវិទ្យាល័យ ដោយពេលនោះនារីជាមិត្តនារីរបស់គេបែកគ្នាទៅរៀបការ ដោយស្វាមីគឺជាមន្ត្រីគយម្នាក់ ជាហេតុធ្វើឲ្យរូបគេមានការឈឺចាប់យ៉ាងខ្លាំង ។

សុភ័ក្រ បានបញ្ជាក់ថា "ស្នេហ៍ដំបូងនេះ ខ្ញុំឈឺចិត្តខ្លាំងណាស់ ប៉ុន្តែការសម្លាប់ខ្លួនគ្មាននៅក្នុងគំនិតរបស់ខ្ញុំទេ ។ ខ្ញុំបានបង្វែរការឈឺចាប់នេះទៅជាការខំប្រឹង។ គឺថា ឲ្យតែខ្ញុំនឹកឃើញរឿងនេះ គឺខ្ញុំខំប្រឹងរៀន ខំប្រឹងគិតគូរមុខរបរភ្លាម។ ឥឡូវខ្ញុំមានគ្រួសារ មានទ្រព្យធនល្មមនឹងរស់នៅក្នុងជីវភាពមួយសមរម្យ ដូចគេដូចឯងដែរ"។

នេះគឺជាអ្វី ដែលយុវជនមួយរូបបានចែករំលែក ខណៈដែលរឿងរ៉ាវសម្លាប់ខ្លួន គឺនៅតែជាប្រធានបទមួយដែលសង្គម គួរតែយកចិត្តទុកដាក់បន្ថែមទៀត ។

កាលពីពេលថ្មីៗនេះមហន្តរាយពីរដែលយុវជន និងយុវនារីគួរតែពិចារណា គឺការសម្លាប់ខ្លួនរបស់យុវជនខ្មែរដើមកំណើតវៀតណាម នៅខេត្តពោធិ៍សាត់មួយគូ និង អំពើអត្តឃាតស្នេហ៍នៅក្នុងផ្ទះសំណាក់មួយ ដែលមូលហេតុអំពើអត្តឃាតនេះគឺបណ្តាលមកពីស្នេហា ។

ករណីទីមួយ គឺកើតមានរវាងយុវជន និង យុវនារីមួយរូប ដែលមានទំនាក់ទំនងស្នេហ៍នឹងគ្នា ប៉ុន្តែត្រូវបានប៉ុនប៉ងបំបែកដោយគ្រួសារ ដោយសារតែវណ្ណៈនៅក្នុងសង្គម។ អំពើនេះគឺកើតមានឡើងរវាងយុវជន និង យុវនារី ដែលមានវ័យមិនដល់ ២០ ឆ្នាំនៅឡើយទេ ។

ករណីទីពីរ គឺជាអំពើហិង្សាស្នេហ៍ដែលខាងប្រុសមានវ័យជាង ២០ ឆ្នាំ និង ខាងស្រីក្រោម២០ឆ្នាំ ។ ករណីនេះ ខាងប្រុសចាក់ខាងស្រីរបួស រួចហើយ ចាក់សម្លាប់ខ្លួនឯងជាក្រោយ ប៉ុន្តែមិនទាន់សំរេច ហើយត្រូវបានក្រុមគ្រួសារជនរងគ្រោះ និងអាជ្ញាធរដឹកទៅសង្គ្រោះនៅមន្ទីរពេទ្យ ខណៈដែលជោគវាសនារបស់ពួកគេមិនដឹងជាយ៉ាងណានៅឡើយមកដល់ពេលនេះ។

ជុំវិញបញ្ហាអត្តឃាតនេះ លោក អ៊ុំ ផ្លាទីន អ្នកចិត្តវិទ្យាឯករាជ្យមួយរូប បានមានប្រសាសន៍ថា ជាទូទៅអ្នកដែលមានបញ្ហានេះ គឺដោយសារតែពួកគាត់ មានជំងឺធ្លាក់ទឹកចិត្តខ្លាំង ហើយដោយឡែកសង្គមកម្ពុជាជាទូទៅ ហាក់និយាយតិចណាស់ អំពីដំណោះស្រាយនៃបញ្ហាស្នេហារនេះ ។

លោកបានមានប្រសាសន៍ថា នៅក្នុងសង្គមកម្ពុជាសូម្បីតែនៅក្នុងអក្សរសិល្ប៍មួយចំនួន ក៏មិនឲ្យតម្លៃ មិនឲ្យដំណោះស្រាយអ្វីដែរ អំពីបញ្ហាស្នេហានោះ ជាក់ស្តែងដូចជារឿងទុំទាវ នៅក្នុងរឿងវីដេអូ នៅក្នុងចំរៀងខារ៉ាអូខេអីជាដើម គឺអត់មានដំណោះស្រាយអ្វីទេចំពោះបញ្ហាស្នេហា។ ដំណោះស្រាយរបស់គេជុំវិញវិបត្តិស្នេហ៍នេះ គឺមានតែការស្លាប់នេះប៉ុណ្ណោះ រីឯគ្រួសារ ក៏មិនគាំទ្រឲ្យមានស្នេហាដែរ ដូច្នេះហើយ បានជាយុវវ័យយកបញ្ហាអត្តឃាតនេះជាត្រីមុខ ។

លោកបានបន្តទៀតថា ដើម្បីដោះស្រាយបញ្ហានេះ សង្គមកម្ពុជា គួរតែបង្កើនការអប់រំយុវវ័យអំពីបញ្ហាស្នេហានេះ ហើយសង្គមក៏ដូចជាគ្រួសារ គួរកុំស្តីបន្ទោស បើសិនជាយុវវ័យ គាត់កំពុងតែមានបញ្ហាស្នេហ៍នេះ បញ្ហាសំខាន់ គឺផ្តល់ដំណោះស្រាយនិងឲ្យគាត់ចេះគិតពិចារណា ។

លោកបានបញ្ជាក់ថា "ស្នេហា គឺជាធម្មជាតិ យើងមិនអាចហាមយុវវ័យមិនឲ្យមានស្នេហានោះទេ តែសំខាន់គឺយើងអប់រំគេ ឲ្យមានស្នេហាមួយដែលមានភាពថ្លៃថ្នូរ ស្នេហាមួយដែលត្រឹមត្រូវហើយចេះពិចារណា" ៕

**ដោយ អរិយបុត្រ**

# លំហាត់ប្រាណសម្រាប់ស្ត្រីមានផ្ទៃពោះ



រូបថតៈ លីហៀង

ការហាត់ប្រាណ ក្នុងពេលមានគភ៌ មិនត្រឹមតែជួយឲ្យ អ្នកមានអារម្មណ៍ស្រួលខ្លួនប៉ុណ្ណោះទេ តែជួយឲ្យសន្លាក់ និង សាច់ដុំនៅពេលសម្រាលកូនប្រព្រឹត្តទៅបានដោយស្រួលផងដែរ។ ដូច្នេះ ស្ត្រីមានផ្ទៃពោះត្រូវធ្វើលំហាត់ប្រាណឲ្យបានរាល់ថ្ងៃ។

លក្ខណៈ នៃការហាត់ប្រាណក្នុងពេលមានគភ៌៖

១. គួរតែចាប់ផ្តើម ធ្វើការហាត់ប្រាណនៅពេលណាដែលអ្នកដឹងថាមានផ្ទៃពោះ ឬ ពេលដែលអ្នកចង់ធ្វើ។ អ្នកអាចចាប់ផ្តើមធ្វើលំហាត់ប្រាណចាប់ពីផ្ទៃពោះ អាយុពី១៦សប្តាហ៍ឡើងទៅបាន។

២. អ្នកគួរធ្វើការ ហាត់ប្រាណរយៈពេល ១៥-២០នាទីក្នុង១ថ្ងៃទៅតាមកំលាំងកាយរបស់អ្នក។

៣. សូមកុំញ៉ាំអាហារ មុនពេលចាប់ផ្តើមហាត់ប្រាណ។ បើចង់ញ៉ាំ អ្នកត្រូវកំរិតការញ៉ាំ ឲ្យបានតិចតួចត្រឹមអាហារសម្រន់ដូចជា នំប៉័ងក្រៀមមួយដុំតូចបានហើយ។

៤. សូមបត់ជើងតូច និង ធំឲ្យហើយមុនពេលហាត់ប្រាណ។

៥. សូមកុំ ធ្វើការហាត់ប្រាណប្រសិនបើមានសញ្ញាគំរាមរលូត និង ប្រវត្តិរលូត ឬសម្រាលកូនមិនគ្រប់ខែ។

៦. សូមកុំ ធ្វើការហាត់ប្រាណហួតទាល់តែហត់ខ្លាំង ឬដកដង្ហើមមិនដល់គ្នា។

៨. ប្រសិនបើអ្នកមានអារម្មណ៍ថាមានឈឺពោះ ឬ ស្បូនចំកោងក្នុងពេលធ្វើការហាត់ប្រាណនេះ សូមបញ្ឈប់ ហើយសម្រាកមួយរយៈ។

៨. សូមប្រុងប្រយ័ត្ន នៅពេលធ្វើលំហាត់ប្រាណ ក្នុងសប្តាហ៍ទី១ និងសប្តាហ៍ចុងក្រោយនៃផ្ទៃពោះ ។

ចំណាំ៖

មុននឹងចាប់ផ្តើម ធ្វើលំហាត់ប្រាណស្ត្រីមានផ្ទៃពោះ ត្រូវទៅមន្ទីរពេទ្យនឹងសួរយោបល់ពីគ្រូពេទ្យអំពីវិធីលំហាត់ប្រាណមួយចំនួន។ ព្រោះចលនាខ្លះអាចធ្វើឲ្យមានផលប៉ះពាល់ ចំពោះទារកក្នុងផ្ទៃ។

សញ្ញាគ្រោះថ្នាក់ ពេលមានផ្ទៃពោះ៖

- *ទម្ងន់របស់ស្ត្រីកើនឡើងមិនគ្រប់គ្រាន់ (ត្រូវកើនឡើង៨គីឡូក្រាមក្នុងអំឡុងមានផ្ទៃពោះ)*
- *មានភាពស្លេកស្លាំង (ត្រូវទាញត្របកភ្នែកក្រោមមើលបើឃើញមានពណ៌សស្លាំង ឬស្លេកនោះ គឺមានន័យថាខ្វះឈាមក្រហម)*
- *មានការអស់កម្លាំង ឬ ហត់ដង្ហក់។*
- *ហើមមុខ ដៃ ជើង។*
- *ទារកក្នុងផ្ទៃមានចលនាតិចឬគ្មានចលនាសោះ?*

បើមានសញ្ញាគ្រោះថ្នាក់ ដូចខាងលើ ត្រូវទៅមន្ទីរពេទ្យដើម្បីពិនិត្យផ្ទៃពោះជាបន្ទាន់ ទោះបីជាមិនទាន់ដល់ថ្ងៃណាត់ជួបគ្រូពេទ្យក៏ដោយ៕

( ដកស្រង់ចេញពីសៀវភៅ ការថែទាំផ្ទៃពោះរបស់អង្គការរ៉ាក់)

# ខួប២០ឆ្នាំព្រះសហគមន៍បឹងទំពុន

គ្រីស្តបរិស័ទជាង ៦០០នាក់បានមកចូលរួមអបអរសាទរខួបទី២០ឆ្នាំនៃការកកើតព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពុន នារាជធានីភ្នំពេញក្រោមអធិបតីភាព របស់លោកអភិបាលភូមិភាគភ្នំពេញ អូលីវីយេ ដឺ្មត អឺស្លែរ រួមជាមួយអាជ្ញាធរឃុំសង្កាត់ ក្រសួងធម្មការ និង សាសនា និងតំណាងពិហិសាសនាជាច្រើនរូបទៀត កាលពីថ្ងៃទី៣០វិច្ឆិកានេះ។

លោកសេន័យឆាល់ វ៉ាំងសង់ ជាបូជាចារ្យទទួលខុសត្រូវ ព្រះសហគមន៍នេះ កាលពីដើមឆ្នាំ ២០១៤ កន្លងទៅបានមានប្រសាសន៍ថា ៖ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺព្រះសហគមន៍នេះ គឺជាកន្លែងប្រមូលផ្តុំជាតិសាសន៍នានា ក្រុមគ្រួសារបព្វជិត បព្វជិតា មានសកម្មភាពសង្គហៈ សកម្មភាពអប់រំជំនឿ និងអប់រំទូទៅ និង មានអង្គការផ្សេងៗដែលមានទំនាក់ទំនងជាមួយព្រះសហគមន៍ដែលប្រៀបបានទៅនឹងស្រុកកាលីឡេ នៅសម័យព្រះយេស៊ូដែរ។

លោកបន្តទៀតថា ក្រុមទាំងអស់នោះបានជំរុញឲ្យព្រះវិហារនេះ មានជីវិត និង បានបង្ហាញពីជីវិតដែលមកពីព្រះជាម្ចាស់ ដែលបានសព្វព្រះហឫទ័យ ប្រទានធម៌មេត្តាករុណា របស់ព្រះអង្គដល់មនុស្សជាច្រើន។ លោកសំណូមពរឲ្យស្ថាបនីមួយៗ ខិតខំបន្តបេសកកម្មរបស់ខ្លួន ឲ្យកាន់តែរីកចម្រើន និង ដោយតាមព្រះហឫទ័យព្រះជាម្ចាស់ដែរ។

ខួប២០ឆ្នាំនេះ ចាប់ផ្តើមឡើងដោយមានអភិបូជាដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលព្រះអង្គប្រោសប្រទានពរដល់ព្រះសហគមន៍នេះរហូតមក។ក្នុងពិធីនោះដែរ លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ក្នុងធម្មទេសនាថា គ្រប់សកម្មភាព និងការរីកចម្រើនរបស់ព្រះសហគមន៍ គឺជាវត្តមានរបស់ព្រះជាម្ចាស់។

លោកអភិបាលបន្តថា ២០ឆ្នាំ គឺជាពេលវេលាមួយ ដែលយើងមានកម្លាំង ក្នុងការរៀបចំអនាគតរបស់យើងបន្ថែមទៀត ដោយគិតលើ៤ចំណុច ក្នុងរដូវរង់ចាំនេះគឺ៖១) យើងជាគ្រីស្តបរិស័ទ ត្រូវប្រុងស្មារតីជានិច្ចដើម្បីមើលឃើញអ្វីៗ ដែលព្រះជាម្ចាស់រង់ចាំពីយើង គឺមើលឃើញសេចក្តីត្រូវការរបស់អ្នកដទៃ។ ២) ជាពេលវេលានៃអំណរសប្បាយដោយ



លោកអភិបាលអូលីវីយេ ថតរូបអនុស្សាវរីយ៍ជាមួយគ្រីស្តបរិស័ទ។ សុធីរិទ្ធិ

រួមជាមួយព្រះនាងម៉ារីដែលរង់ចាំព្រះយេស៊ូប្រសូត្រ និង ប្រគល់ព្រះយេស៊ូឲ្យយើងទាំងអស់គ្នារីឯយើងវិញយើងបានទទួលតួនាទីជាគ្រីស្តទូត និង សាសនទូតរបស់ព្រះអង្គ។ ដូចនេះតើយើងធ្វើដូចម្តេចដើម្បីជូនព្រះយេស៊ូចូលទៅក្នុងសង្គមរបស់យើង ? ៣)ជាពេលមួយដើម្បីអធិដ្ឋានសម្រាប់សន្តិភាព និង សេចក្តីសុខសាន្តព្រោះយើងទទួលព្រះយេស៊ូជា ព្រះអម្ចាស់នៃសន្តិភាព។ ហេតុនេះយើងត្រូវគិតដល់អ្នកខ្វះខាតគ្មានទីពឹង និងគិតថាសេចក្តីសង្ឃឹមសុចរិតយុត្តិធម៌ គឺដើរទន្ទឹមគ្នា។ ៤) ជាពេលវេលាបញ្ចេញសកម្មភាពយ៉ាងសកម្ម នៅក្នុងធម៌មេត្តាករុណាដែលយើងបានទទួលពីព្រះជាម្ចាស់ដោយការចែករំលែកធម៌មេត្តាករុណានេះ ដល់បងប្អូនឯទៀតដើម្បីជាសញ្ញាសម្គាល់សម្រាប់មនុស្សជាច្រើនដែលមានបញ្ហានៅក្នុងជីវិត ។

ព្រះសហគមន៍ ព្រះកុមារយេស៊ូបឹងទំពុនកកើតឡើងក្នុងឆ្នាំ១៩៩៣ ដោយមានការជួបជុំ និង អធិដ្ឋានរួមគ្នារបស់គ្រីស្តបរិស័ទពីជំរំចំនួន ៥គ្រួសារ។ ថ្ងៃទី៦មករា២០០៨ ព្រះវិហារត្រូវបានកសាង។ បច្ចុប្បន្ននេះមានគ្រីស្តបរិស័ទកើនឡើង ប្រមាណជាង ៤០០នាក់៕

**ដោយដាលីស**

# រៀនទីណាក៏ដូចជាទីណា ឲ្យតែរៀនពិតប្រាកដមានចំណេះមានបទពិសោធន៍និងមានសមត្ថភាព




លោក គង់ គឹមស្រ៊ង អ្នកសំរបសំរួលនៃអង្គការសហភាពអភិរក្សអន្តរជាតិ ដើម្បីអភិរក្សធម្មជាតិ (IUCN)។ រូបថត: អរិយបុត្រ

យុវជន និង សាធារណៈជននៅកម្ពុជាភាគច្រើនគឺនិយមឲ្យតម្លៃច្រើនទៅលើការសិក្សា នៅក្រៅប្រទេស ហើយតែងស្វះស្វែងរកការសិក្សានៅទីនោះតាមមធ្យោបាយផ្សេងៗ ប៉ុន្តែគុណភាព និង សមត្ថភាពអ្នកដែលទទួលការអប់រំនៅក្នុងប្រទេស ក៏មិនអន់ប៉ុន្មានឡើយ ដូច្នេះដើម្បីឲ្យជ្រាបពីបញ្ហានេះ **អ្នកនាំសារ** សូមណែនាំមិត្តអ្នកអាន ឲ្យស្តាប់យោបល់អ្នកជំនាញកម្ពុជាមួយរូប គឺ លោក **គង់ គឹម ស្រ៊ង** អ្នកសំរបសំរួល នៃអង្គការសហភាពអភិរក្សអន្តរជាតិ ដើម្បីអភិរក្សធម្មជាតិ (IUCN)។

**អ្នកនាំសារ ៖** អង្គការសហភាពអភិរក្សអន្តរជាតិដើម្បីអភិរក្សធម្មជាតិ គឺជាអង្គការអភិរក្សអន្តរជាតិមួយ តើលោកបញ្ចប់ ការសិក្សានៅប្រទេសណាដែរ ទើបបានមានសមត្ថភាពដឹកនាំការងារ នៅស្ថាប័នមួយនេះបាន ?

**លោក គង់ គឹមស្រ៊ង ៖** អូហ៍! អត់ទេ ខ្ញុំរៀនតែនៅក្នុងស្រុកប៉ុណ្ណោះដោយខ្ញុំរៀន និង ទទួលបរិញ្ញបត្រ ផ្នែកវិទ្យាសាស្រ្តរុក្ខាប្រមាញ់ និង ក្រោយមកទៀត ទើបបន្តយកអនុបណ្ឌិតផ្នែកគ្រប់គ្រងធនធានធម្មជាតិ ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំការដូងយើងនេះប៉ុណ្ណោះ ។

**អ្នកនាំសារ ៖** សព្វថ្ងៃនេះសារធារណៈជននានានៅកម្ពុជា ជាពិសេសគឺយុវជន គឺឲ្យតម្លៃខ្លាំង ទៅលើការសិក្សានៅក្រៅប្រទេស តើលោកយល់យ៉ាងណា ?

**លោក គង់ គឹមស្រ៊ង ៖** វាគឺជារឿងល្អដែលអាចសិក្សានៅក្រៅប្រទេសបាន ហើយសម្រាប់អ្នក ដែលទទួលបានអាហារូបករណ៍ចេញទៅក្រៅល្អទីមួយគឺសម្រួលដល់កត្តាជីវភាព ចំណេញថវិការច្រើនប៉ុន្តែសម្រាប់អ្នកដែលមានលទ្ធភាពបញ្ជូនកូនចេញទៅក្រៅ គឺគេបានក្រេឌីតល្អ ហើយយុវជននោះនឹងទទួលបានបទពិសោធន៍ល្អមែន ។ ប៉ុន្តែសម្រាប់និស្សិតឬប្អូនៗដែលនៅមិនទាន់មានឱកាស ឬសមត្ថភាពចេញទៅសិក្សា នៅក្រៅប្រទេសសូមកុំអាក់អន់ស្រពន់ចិត្ត គួរតែខំប្រឹងសិក្សានៅក្នុងប្រទេស។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ ខ្ញុំមើលឃើញថា ការអប់រំនៅទីណាក៏ដូចជាទីណាដែរ អ្វីដែលសំខាន់ គឺយើងយកចិត្តទុកដាក់រៀនសូត្រដោយខ្លួនយើង ការខិតខំស្វែងរកបទពិសោធន៍ព្យាយាមយកចំណេះប្រើប្រាស់ដែលរៀនពីសាលាយកមកអនុវត្ត ។

**អ្នកនាំសារ ៖** តើលោកអាចចែករំលែកពីបទពិសោធន៍លោកត្រួសៗទៅមិត្តអ្នកអានយើងបន្តិចបានទេ?

**លោក គង់ គឹមស្រ៊ង ៖** ខ្ញុំអាចនិយាយបានថា ខ្ញុំបានចាប់ផ្តើមធ្វើការដំបូងតាំងពី អ្នកស្ម័គ្រចិត្តនៅអង្គការមួយដោយមិនគិតពីថវិការទេ។ អ្វីដែលខ្ញុំគិតដំបូង គឺបទពិសោធន៍ ពីព្រោះថា កាលណាយើងមានបទពិសោធន៍ ហើយ ទើបយើងអាចគិតអំពីតម្លៃខ្លួនយើងប៉ុណ្ណាៗបាន ចាំចរចារជាមួយនឹងគេរឿងប្រាក់បៀវត្សរ៍ ។

**អ្នកនាំសារ ៖** តើលោកអាចផ្តល់សារបន្តិចដល់យុវជន ដែលកំពុងតែស្រមៃរឿងអាហារូបករណ៍ ចេញទៅក្រៅប្រទេសនេះបន្តិចបានទេ ?

**លោក គង់ គឹមស្រ៊ង ៖** ខ្ញុំសូមលើកទឹកចិត្តឲ្យប្អូនៗយុវជន និង យុវនារី ជានិស្សិត ដែលកំពុងតែបន្តការសិក្សានៅក្នុងប្រទេស កុំសម្លឹងមើលតែអាហារូបករណ៍នៅក្រៅប្រទេសពេក ។ ខ្ញុំគិតថាយើងត្រូវខំរៀនខ្លួនយើងសិនពោលគឺត្រូវមានគំនិតថា យើងម្នាក់ៗកុំអង្គុយរង់ចាំគេយកអ្វីមកឲ្យយើង។ យើងត្រូវតែខំដោយខ្លួនឯង ត្រូវស្វែងរកការស្វែងយល់ការស្វែងរកការចូលរួមការអនុវត្តការងារឲ្យបានច្រើន ។

**អ្នកនាំសារ ៖** តើលោកយល់យ៉ាងណាដែរអំពីការអប់រំនៅក្នុងប្រទេសកម្ពុជាយើងនាពេលសព្វថ្ងៃនេះ ?

**លោក គង់ គឹមស្រ៊ង ៖** ខ្ញុំយល់ថា ការអប់រំ និង គុណភាពនៃការបណ្តុះបណ្តាលនៅបណ្តាសាកលវិទ្យាល័យ ឬ ក៏ស្ថាប័នអប់រំមួយចំនួននៅកម្ពុជា គឺមានកម្មវិធីមានគុណភាព ប្រហាក់ប្រហែលនឹងការអប់រំនៅស្រុកគេដែរ។ ខ្ញុំយល់ថា ជួនកាលយើងរៀននៅក្នុងប្រទេស គឺយើងអាចរៀនបានច្រើនជាងអ្នកដែលរៀន នៅក្រៅប្រទេសផងក៏ថាបាន ពីព្រោះថា យើងរៀននៅស្រុកគេ យើងអាចរៀនតែមួយភាសាទេ តែនៅក្នុងស្រុកយើងវិញគឺអាចរៀនបានទាំងភាសាជាតិ ភាសាអង់គ្លេស ហើយនិងភាសាផ្សេងទៀតក៏បាន ដោយសារតែឯកសារយើងមានភាសាខុសៗគ្នា។ សម្រាប់អ្នកដែលរៀននៅក្រៅប្រទេសយូរ ជាពិសេស គឺតាំងពីតូចមក ជួនកាលគាត់អត់យល់ពីបរិបទ នៅក្នុងប្រទេសយើង ប៉ុន្តែសម្រាប់អ្នកដែលរៀនបរិញ្ញាប័ត្រនៅក្នុងស្រុកយើង ហើយទៅបន្តនៅស្រុកគេថែមទៀតនោះ ប្រហែលជាមិនអីទេ ។

**អ្នកនាំសារ ៖** សម្រាប់លោកផ្ទាល់ដែលរៀននៅក្នុងស្រុកបែបនេះ ប៉ុន្តែលោកធ្វើការជាមួយនឹងបរទេស តើមានការលំបាកអ្វីដែរឬទេ ?

**លោក គង់ គឹមស្រ៊ង ៖** សម្រាប់ខ្ញុំដូចជាមិនមានការលំបាកទេ តែបើនិយាយថាលំបាកនោះ គឺរឿងភាសាបន្តិច ពីព្រោះជួនកាល ត្រូវទំនាក់ទំនងជាមួយនឹងជនជាតិខ្លះ គាត់និយាយពិបាកស្តាប់បន្តិច ជាពិសេស ដូចជា ឥណ្ឌា នេប៉ាល់ ប៉ាគីស្ថាន ប៉ុន្តែសំខាន់ គឺយើងខំ យើងយកចិត្តទុកដាក់។ ឥឡូវនេះ ខ្ញុំអាចធ្វើការបានជាមួយពួកគេបានយ៉ាងទូលំទូលាយ ។ ក្រៅពីភាសា គឺខ្ញុំអាចលំបាកដែរ គឺរឿងវប្បធម៌នៃជាតិសាសន៍ បញ្ហានេះសំខាន់ដែរ ដែលទាមទារថាត្រូវតែសិក្សាស្វែងយល់បន្ថែមទៀត ។

**អ្នកនាំសារ ៖** តើអង្គការសហភាពអភិរក្សអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (IUCN) ជាអង្គការអន្តរជាតិ ឬយ៉ាងម៉េច?

**លោក គង់ គឹមស្រ៊ង ៖** អង្គការសហភាពអភិរក្សអន្តរជាតិ ដើម្បីអភិរក្សធម្មជាតិ (IUCN) ជាអង្គការអន្តរជាតិមួយ ដែលកំពុងតែធ្វើការផ្នែកអភិរក្សសហគមន៍ជាដើម នៅក្នុងប្រទេសជាង ១៩០ ប្រទេស ដែលមានអ្នកជំនាញការគ្រប់ជាតិសាសន៍ សរុបចំនួនជាង ១០.០០០នាក់ នៅពេញពិភពលោកទាំងអឺរ៉ុប អាស៊ី អាហ្វ្រិក ។ល។

**អ្នកនាំសារ ៖** អង់គ្លេស គឺ ជាភាសាយានមួយដ៏សំខាន់ សម្រាប់ទំនាក់ទំនង ដែលយុវជនយើងយល់តែនៅតែមានបញ្ហាលំបាក នៅក្នុងការចេះនិយាយ ចេះស្តាប់ តើលោកអាចចែករំលែកចំណុចនេះបន្តិចបានទេ ?

**លោក គង់ គឹមស្រ៊ង ៖** រឿងរៀនភាសាមួយសូមកុំខ្លាចខុស។ ប្អូនៗ និស្សិតគឺអាចមានអារម្មណ៍ថា មានការភ័យខ្លួនឯង នៅក្នុងការប្រើប្រាស់ភាសានេះដោយសារតែខ្លាចថាពេលនិយាយចេញទៅគេស្តាប់មិនបាន គេមិនយល់និយាយមិនត្រូវ។ ការគិតបែបនោះគឺខុស រៀនភាសាកុំខ្មាស់ កុំខ្លាចត្រូវតែហ៊ានទំនាក់ទំនង ហ៊ាននិយាយទៅគេ កុំខ្លាចគេសើច ប៉ុន្តែសម្រាប់ភាសាសរសេរ គឺត្រូវប្រយ័ត្នបន្តិចពោលគឺត្រូវត្រួតពិនិត្យ ឲ្យបានហ្មត់ចត់ ៕

**ដោយអរិយបុត្រ**

# កម្មករនិងកម្មការនីមិនរំពឹងនឹងតួរលេខនៃចំណូល ២៥០ ដុល្លារ នៅក្នុងមួយខែនៅឆ្នាំក្រោយ




កម្មករ-កម្មការិនីធ្វើកូដកម្មនៅផ្លូវវេងស្រេង ទាមទារដំឡើងប្រាក់ខែ ១៧៧ដុល្លារ។ រូបថតៈ សហការី

កម្មករ និងកម្មការិនីមួយចំនួនដែលកំពុងបំពេញការងារ នៅក្នុងទីក្រុងភ្នំពេញបានសំដែងនូវអារម្មណ៍ ត្រេកអរ និង ត្រេតត្រអាល ជាមួយនឹងប្រាក់បៀវត្សរ៍ដែលសមាគមរោងចក្រកាត់ដេរនៅកម្ពុជាអះអាងថា ពួកគេនឹងទទួលបានប្រាក់បៀវត្សរ៍ រហូតដល់ទៅ ២៥០ ដុល្លារនៅក្នុងមួយខែ នៅក្នុងឆ្នាំក្រោយនេះ ។

កញ្ញា ដេត ស្រីនាថ ជាកម្មការិនីរោងចក្រកាត់ដេរមួយរូប នៅផ្លូវវេងស្រេង នៅក្នុងរាជធានីភ្នំពេញ បានអះអាងថា នរណាមិនអរ និង រំភើបយ៉ាងម៉េចបើប្រាក់ខែមួយខែឡើងដល់ទៅ ២៥០ ដុល្លារ ប៉ុន្តែកញ្ញា មិនរំពឹងដែរ ដោយសារតែតួរលេខនេះវាដូចជាខ្ពស់ពេក ច្រើនពេក ។

ស្រីនាថ បានបញ្ជាក់ថា "ឥឡូវខ្ញុំអង្គុយដេរ ឡើងចង់ក្រិនគូទហើយ បានត្រឹមតែ ១៨០ ដុល្លារ ទៅ ២០០ ដុល្លារនៅក្នុងមួយខែ ចុះអា៥០ ទៅ ៧០ ដុល្លារនេះបានមកពីណា ? "។

ស្រីនាថ បានឲ្យដឹងថា នៅក្នុងពេលបច្ចុប្បន្ននេះ កញ្ញាបានចំណាយពេលអង្គុយដេរនេះ ប្រហែលជា ១០ ម៉ោងនៅក្នុងមួយថ្ងៃ ដើម្បីជាថ្នូរនឹងប្រាក់ខែ ១៨០ ដុល្លារ ទៅ ២០០ ដុល្លារនេះដោយនៅក្នុងនោះប្រាក់ខែគោល គឺតែ១០០ដុល្លារទេ តែបានថ្លៃអាហារ ថ្លៃធ្វើដំណើរតិចតួច បូកនឹងលុយថែមម៉ោងអីទើបបានទទួលប្រាក់ចំណូលជិត២០០ដុល្លារនេះ ។ តែដល់ពេលឮវិទ្យុគេផ្សាយថា ២៥០ ដុល្លារអ្នកនាងអរណាស់។

ស្រីនាថ បានបន្តទៀតថា "ទោះបីជាពិត ឬមិនពិតយ៉ាងណា ខ្ញុំនឹងចាំមើល"។

លោកស្រី នឹម ថង ជាកម្មការិនីរោងចក្រ នៅម្តុំផ្សារឯករាជ្យ ផ្លូវវេងស្រេងនេះដែរបានឲ្យដឹងថា បើរោងចក្រគេតម្លើងឲ្យដល់ ២៥០ ដុល្លារ មែននោះ ខ្ញុំគិតថា ច្រើនសមរម្យសម្រាប់ខ្ញុំ។

លោកស្រី បានបញ្ជាក់ថា "បើឆ្នាំក្រោយ ខ្ញុំទទួលប្រាក់ខែថ្មី ដល់ ២៥០ដុល្លារនេះមែន ខ្ញុំគិតថា អាចសន្សែសន្សំបានខ្លះដែរ"។

លោកស្រី បានបន្តទៀតថា សព្វថ្ងៃនេះ លោកស្រីបានទទួលប្រាក់ខែនៅក្នុងមួយខែជាមធ្យមត្រឹមតែ១៥០ ដុល្លារប៉ុណ្ណោះ ហើយបើបូកជាមួយនឹងប្រាក់ចំណូលពីស្វាមី ដែលជាអ្នករត់រ៉ឺម៉ក គឺល្មមតែគ្រប់គ្រាន់ឲ្យកូនទៅរៀន ថ្លៃម្ហូប ថ្លៃថ្នាំព្យាបាលកូន និង ខ្លួនឯង ថ្លៃជួលផ្ទះស្នាក់នៅ តែប៉ុណ្ណោះ តែបើរោងចក្រអាចតម្លើងតចឹងមែន គឺសមរម្យណាស់សម្រាប់ខ្ញុំ។

ជុំវិញប្រាក់បៀវត្សរ៍ មួយខែ២៥០ ដុល្លារនេះ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានអះអាង នៅក្នុងសេចក្តីថ្លែងការមួយកាលពីពេលថ្មីៗកន្លងទៅនេះថា សរុបមក ចាប់ពីខែមករា ឆ្នាំ២០១៥ តទៅ កម្រិតប្រាក់ឈ្នួលប្រចាំខែសរុប ដែលកម្មករអាចមានលទ្ធភាពនឹងទទួលបាន គឺចន្លោះពី ២២៥ ដុល្លារទៅ ២៥០ ដុល្លារ។

តាមរយៈសេចក្តីថ្លែងការណ៍កាលពីពេលថ្មីៗកន្លងទីនេះ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានអះអាងថាប្រាក់បៀវត្សរ៍កំរិតចន្លោះពី ២២៥ ដុល្លារទៅ ២៥០ដុល្លារនេះ គឺបានមកពីប្រាក់ឈ្នួលគោល ប្រាក់ឧបត្ថម្ភស្នាក់នៅ ឬប្រាក់ធ្វើដំណើរ ប្រាក់រង្វាន់ធ្វើការងារទៀងទាត់ ប្រាក់រង្វាន់អតីតភាពការងារ ប្រាក់រង្វាន់សម្រាប់ការផលិតដល់ ឬ លើសគោលដៅ ប្រាក់ជំនាញ ឬប្រាក់តួនាទី ប្រាក់ធ្វើការថែមម៉ោង និងថ្លៃបាយពេលថែមម៉ោង និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀត តាមគោលនយោបាយ នៃរោងចក្រនីមួយៗ។

នេះគឺជាគោលការណ៍ នៃការកំណត់ប្រាក់បៀវត្សរ៍ ដែលសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានឲ្យដឹង។ ប៉ុន្តែជាទូទៅកម្មករនិងកម្មការនីនៅកម្ពុជា មិនសូវជាយល់ អំពីប្រព័ន្ធរៀបចំប្រាក់បៀវត្សរ៍របស់ខ្លួននោះទេ ។

អ្នកស្រី នឹម ថង បានឲ្យដឹងថា មកដល់ពេលនេះ លោកស្រីមិនដឹងថា រោងចក្រគេរៀបចំប្រាក់បៀវត្សរ៍លោកស្រីយ៉ាងណានោះទេ ។ លុយ ១៥០ដុល្លារ នៅក្នុងមួយខែ ដែលលោកស្រីដឹង គឺ ប្រាក់ខែគោលលុយថែមម៉ោងបន្តិចបន្តួច និង លុយថ្លៃធ្វើដំណើរ ប៉ុន្តែអាផ្សេងៗ ដូចមិនទាន់ដឹងទេ ។

កញ្ញា ដេត ស្រីនាថ ក៏មិនបានដឹងស៊ីជំរៅរឿងនេះផងដែរ អំពីប្រភពនៃប្រាក់បៀវត្សរ៍របស់កញ្ញា ដោយអះអាងថា តាមពិតកញ្ញា អាចទទួលប្រាក់បៀវត្សរ៍ច្រើនជាងនេះ ប៉ុន្តែរោងចក្រគេកាត់ពន្ធលើប្រាក់ចំណូលខ្លះរបស់កញ្ញា ។

យោងទៅតាមការសំរេច របស់ក្រសួងការងារ ចាប់ពីខែ មករា ឆ្នាំ ២០១៥ តទៅកម្មករឬកម្មការិនីរោងចក្រកាត់ដេរមួយរូប គឺត្រូវទទួលប្រាក់ខែគោលទាបបំផុត គឺ ១២៨ ដុល្លារនៅក្នុងមួយខែ ។

នៅកម្ពុជានាពេលសព្វថ្ងៃនេះ វិស័យឧស្សាហកម្មកាត់ដេរ គឺមាន៩៦០ រោងចក្រ ដែលកំពុងតែបានផ្តល់ការងារធ្វើដល់ប្រជាពលរដ្ឋ ប្រមាណជា ៦២០.០០០ នាក់ ខណៈដែលឧស្សាហកម្មនេះ បាននាំចេញ មានតម្លៃប្រមាណជា ៤,៤៤ ពាន់លានដុល្លារ នៅក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៤ នេះ ពោលគឺមានការកើនឡើងប្រមាណជា ៧៦ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីដើមឆ្នាំ២០១៣ ៕

**ដោយអរិយបុត្រ**

# ព័ត៌មានទូទៅ

## រាជរដ្ឋាភិបាលកម្ពុជារឹបអូសដីសម្បទាន ជាង ៥១.៧៨៦ ហ.តពីក្រុមហ៊ុន ៩

រាជរដ្ឋាភិបាលកម្ពុជាបានរឹបអូសដីសម្បទានសេដ្ឋកិច្ចជាង ៥១.៧៨៦ ហាតពីក្រុមហ៊ុន ៩ នៅក្នុងភូមិសាស្ត្រខេត្ត៨ថែមទៀត។ នេះបើយោងទៅតាមអនុក្រឹត្យពីរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

ប្រភពដដែលបានឲ្យដឹងថា ដីសម្បទានសេដ្ឋកិច្ចទាំងនោះ គឺនៅក្នុងខេត្តមណ្ឌលគីរី ខេត្តកំពង់ស្ពឺខេត្តព្រះសីហនុ ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តឧត្តមានជ័យ និង ខេត្តបាត់ដំបង និង ក្រចេះ ។

ដីសម្បទាននៅក្នុងខេត្តទាំង ៧ នេះ គឺ មានដូចជាផ្ទៃដីទំហំ ៩.១៦០ ហ.តក្នុងតំបន់ ដែនជម្រកសត្វព្រៃភ្នំព្រេច,ផ្ទៃដី៥.៥៥៩ហ.ត ក្នុងតំបន់ដែនជំរកសត្វព្រៃភ្នំណាមលៀរ, ផ្ទៃដី ៥.០០០ ហ.ត ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគិរី, ផ្ទៃដី ៨.៥៦៨ហ.ត នៅក្នុងឧទ្យានជាតិ ព្រះសុរាម្រិតកុសមៈគិរីរម្យ នៅក្នុងភូមិសាស្ត្រខេត្ត កំពង់ស្ពឺ និង ខេត្តព្រះសីហនុ, ផ្ទៃដី៥៨៨ ហ.តនៅក្នុងដែនជំរកសត្វព្រៃបឹងពែរ នៅក្នុងភូមិសាស្ត្រ ខេត្តព្រះវិហារ និង ខេត្តកំពង់ធំ, ផ្ទៃដី៨.២០០ហ.ត ក្នុងតំបន់ដែនជម្រកសត្វព្រៃ គូលែនព្រហ្មទេព ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ និង ផ្ទៃដីទំហំ ៤.៥៥៧ ហ.ត ក្នុងតំបន់ដែនជំរកសត្វព្រៃ រនាមដូនសំ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង។

ប្រភពដដែលបានឲ្យដឹងថា ផ្ទៃដី ៦០៩ ហ.ត នៅក្នុងភូមិសាស្ត្រក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិតកុសមៈគីរីរម្យ ក្នុងខេត្តកំពង់ស្ពឺ ត្រូវបានរាជរដ្ឋាភិបាលដកហូត៥៨៩ហ.តដោយទុកសិទ្ធិឲ្យវិនិយោគត្រឹមតែ ២០ហ.ត តែប៉ុណ្ណោះ ។ ខណៈដែលដីទំហំ ៩.៧៨០ហ.ត ស្ថិតនៅក្នុងតំបន់ដែនជំរកសត្វព្រៃស្នួល ខេត្តក្រចេះ ត្រូវបានរឹបអូសចំនួន ៩.៥៦៥ ហ.ត ដោយទុកសិទ្ធិវិនិយោគ ឲ្យត្រឹមតែ ២១៥ ហ.ត តែប៉ុណ្ណោះ៕

## ធនាគារអភិវឌ្ឍន៍អាស៊ីប្រកាសឈប់ផ្តល់ជំនួយឥតសំណងដល់កម្ពុជា

ធនាគារអភិវឌ្ឍន៍អាស៊ី ដែលជាស្ថាប័នហិរញ្ញវត្ថុប្រចាំទ្វីបអាស៊ីដ៏ធំ បានអះអាងថានៅក្នុងរយៈពេល២-៣ ឆ្នាំចុងក្រោយនេះខ្លួនលែងផ្តល់ជំនួយឥតសំណងដល់កម្ពុជាហើយ ។

លោក អេរិច ស៊ីដវិក នាយកធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំនៅក្នុងប្រទេសកម្ពុជា បានមានប្រសាសន៍នៅក្នុងសន្និសីទកាសែត ប្រកាសយុទ្ធសាស្ត្រភាពជាដៃគូរយៈពេល ៥ ឆ្នាំ ដើម្បីគាំទ្រ ដល់កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា នៅប្រទេសកម្ពុជាថា នេះគឺដោយសារតែប្រទេសកម្ពុជាជាប្រទេស ដែលបានងើបផុតពីស្ថានភាពដែលប្រទេសមួយទទួលបានកម្ចីផង ជំនួយឥតសំណងផង។

លោកបានបញ្ជាក់ថា "កម្ពុជាលែងទទួលជំនួយឥតសំណងនេះប្រហែលជា២-៣ឆ្នាំមកហើយ ដោយសារតែស្ថានភាពបំណុល មាននិរន្តរភាព ហើយប្រទេសកម្ពុជា បានងើបផុតពីស្ថានភាព ដែលប្រទេសមួយទទួលបានកម្ចីផងជំនួយឥតសំណងផង" ។

លោកបានបន្តទៀតថា ធនាគារអភិវឌ្ឍណ៍អាស៊ីនៅតែបន្តគាំទ្រដល់ប្រទេសកម្ពុជា ប៉ុន្តែតាមរយៈការផ្តល់ហិរញ្ញប្បទានសម្បទានដែលត្រូវសងបំណុលមកវិញ មានរយៈពេលវែង ហើយមានអត្រាការប្រាក់ទាប។

ផ្អែកទៅតាមយុទ្ធសាស្ត្រភាព ជាដៃគូសម្រាប់កម្ពុជានៅក្នុងរយៈពេលពីឆ្នាំ ២០១៤ ដល់ ឆ្នាំ២០១៨ធនាគារអភិវឌ្ឍន៍អាស៊ី បានប្រកាសផ្តល់ជំនួយហិរញ្ញប្បទាន ដែលមានទឹកប្រាក់សរុប ៨០០ លានដុល្លារ ៕

## អាជ្ញាធរវៀតណាមចាប់ខ្លួនអ្នកសរសេរគេហទំព័រប្រឆាំង

អាជ្ញាធរប៉ូលីសវៀតណាម កាលពីចុងខែ វិច្ឆិកា ឆ្នាំ២០១៤ កន្លងទៅបានចាប់ឃុំខ្លួន អ្នកសរសេរលើទំព័រគេហទំព័រម្នាក់ ដែលហ៊ានរិះគន់រដ្ឋាភិបាល និង អាជ្ញាធរនៅក្នុងប្រទេស ។

ក្រសួងសន្តិសុខជាតិ វៀតណាម បានអះអាង នៅក្នុងគេហទំព័ររបស់ខ្លួនថា បុរសដែលត្រូវចាប់ខ្លួន មានឈ្មោះថាហុង លីចឺមានអាយុ៦៥ឆ្នាំ។ ប្រភពដដែលបានអះអាង ថា លោក ហុង លីចឺ ត្រូវបានចាប់ឃុំខ្លួន ចំពោះការចុះផ្សព្វផ្សាយអត្ថបទរិះគន់ និង ផ្សាយព័ត៌មានមិនពិត ជាច្រើននៅលើអនឡាញដែលបានធ្វើឲ្យមានការយល់ច្រឡំ និងធ្វើឲ្យមានការបាត់បង់ការជឿជាក់ ក្នុងចំណោមប្រជាជន ចំពោះភ្នាក់ងាររដ្ឋ និង ភ្នាក់ងារសង្គម។

ការចាប់ខ្លួនរបស់លោក ហុង លីចឺ នេះមិនមែនជាករណីទីមួយដែលអាជ្ញាធរនៅក្នុងប្រទេស វៀតណាម បានធ្វើនោះទេ កន្លងមកមានប្រជាពលរដ្ឋវៀតណាម ដែលហ៊ានចេញមុខរិះគន់រដ្ឋាភិបាលត្រូវបានចាប់ខ្លួន ។

គួររំលឹកដែរថា ការចាប់ខ្លួនលោក ហុង លីចឺ នេះគឺបានធ្វើឡើងក្រោយពេលដែលអាជ្ញាធរ វៀតណាម បានដោះលែងអ្នកសរសេររិះគន់រដ្ឋាភិបាលវៀតណាមមួយរូប កាលពីខែមុន គឺលោក ឃៀន វ៉ាន់ ហៃ ដែលបានរៀបចំធ្វើកូដកម្មអត់អាហារ ដើម្បីតវ៉ាចំពោះការប្រព្រឹត្តអាក្រក់ លើក្រុមអ្នកទោសនយោបាយ។

នេះជាចំណាត់ការ ចុងក្រោយបំផុតក្នុងការបង្ក្រាបលើក្រុមអ្នកនិយាយរិះគន់ប្រឆាំង តែវាត្រូវបានថ្កោលទោសដោយក្រុមសិទ្ធិមនុស្ស និង ក្រុមរដ្ឋាភិបាលបស្ចឹមប្រទេស៕

## ជនរងគ្រោះដោយអេបូឡាកើនដល់ជិត ៧.០០០នាក់ ខណៈវ៉ាក់សាំង កំពុងបន្តស្រាវជ្រាវ

អង្គការសុខភាព ពិភពលោក (WHO) បាននិយាយថា ចំនួនអ្នកស្លាប់ដោយ ជំងឺអេបូឡា នៅអាហ្វ្រិកខាងលិច បានកើនឡើងដល់៦.៩២៨នាក់និងចំនួនអ្នកឆ្លងជំងឺនេះ បានកើនឡើង ជាង ១៦.០០០នាក់ ។

ប្រភពដដែល បានបន្តទៀតថា ជិត២ខែ បន្ទាប់ពីខ្លួនបានចាប់ផ្តើមអនុវត្តផែនការ ដើម្បីបញ្ឈប់ការឆ្លងរាលដាលនៃជំងឺនេះនៅអាហ្វ្រិកខាងលិច ដោយដាក់ជនរងគ្រោះនៃជំងឺនេះ ចំនួន៧០ភាគរយ ឲ្យនៅដាច់ដោយឡែក នៅថ្ងៃ ទី១ ខែធ្នូនៅប្រទេសចំនួន៣ ដែលទទួលរងប៉ះពាល់ខ្លាំងជាងគេបំផុតពីជំងឺនេះគឺនៅប្រទេសហ្គីណេ ប្រទេសសៀរ៉ាឡេអូន និង នៅប្រទេសលីបេរីយ៉ា ។

តាមទិន្នន័យថ្មី បានបង្ហាញថាមានមនុស្សឆ្លងជំងឺនេះ សរុបចំនួន ១៦.១៦៩ នាក់នៅប្រទេសទាំង៣នេះ ហើយចំនួនជាង៣០ករណី នៃការឆ្លងជំងឺនេះគឺនៅបណ្តាប្រទេសផ្សេងទៀតក្រៅពីអាហ្វ្រិក ខាងលិចនេះ។

នៅក្នុងខណៈ ពេលដែលចំនួនជនរងគ្រោះ ដោយសារតែជំងឺអេបូឡានេះ កំពុងតែកើនឡើងនៅអាហ្វ្រិក គេបានអះអាងថា វ៉ាក់សាំងនៃជំងឺនេះ អាចនឹងត្រូវរកឃើញនៅក្នុងរង្វង់ដើមឆ្នាំ ២០១៥ ខាងមុខ ដោយសារតែ ការធ្វើពិសោធន៍ទៅលើអ្នកស្ម័គ្រចិត្ត ២០ នាក់ បានជោគជ័យ ។

ក្រុមអ្នកជំនាញ ផ្នែកសុខាភិបាលបច្ចឹមប្រទេសបានអះអាងថា ទោះបីជាវ៉ាក់សាំងត្រូវបានផលិត ក៏ពិតមែន ប៉ុន្តែដំណាក់កាលដំបូង គឺមិនអាចសម្រាប់មនុស្សទាំងអស់បានទេ គឺសម្រាប់តែអ្នកដែល ជាជនជួរមុខដែលកំពុងតែប្រយុទ្ធប្រឆាំងនឹងជំងឺនេះនៅអាហ្វ្រិកខាងលិចសិន៕

# ពលរដ្ឋកម្ពុជាចង់ឃើញគណបក្សទាំងពីរ



មេដឹកនាំគណៈបក្សធំៗទាំងពីរជួបប្រជុំគ្នានៅព្រឹទ្ធសភា កាលពីថ្ងៃទី ២២ ខែ កក្កដា ២០១

ជុំវិញការវិវដ្តចុងក្រោយ នៃស្ថានភាពនយោបាយនៅក្នុង ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ពលរដ្ឋកម្ពុជា បានបង្ហាញអំពីការពេញចិត្តនឹងស្ថានភាពនយោបាយ នៅក្នុងប្រទេស ប៉ុន្តែពួកគេចង់ឃើញកំណែទម្រង់ពិតប្រាកដ ជាពិសេសគឺអ្វីដែលគណបក្សទាំងពីរ បានសន្យាចំពោះម្ចាស់សន្លឹកឆ្នោត ។

លោក ជិន សេដ្ឋា ជាប្រជាពលរដ្ឋកម្ពុជាមួយរូបដែលមានអាយុ ៤៥ឆ្នាំ បានមានប្រសាសន៍ថា ក្រោយពេលដែលប្រទេស មានស្ថេរភាពនយោបាយគណបក្សទាំងពីរ បានចូលសភារដ្ឋាភិបាលបានធ្វើកិច្ចការដែលរសើបមួយចំនួនផងដែរ ទោះបីជាបញ្ហាវាហាក់ដូចជា មិនទាន់ពេញចិត្តទាំងស្រុងក៏ពិតមែន ។

បើតាមប្រសាសន៍ របស់លោកសេដ្ឋា អ្វីដែលលោកបានមើលឃើញអំពីការប្រែប្រួលមួយរយៈកន្លងមកគឺមានដូចជា ការបោសសំអាតមន្ត្រីមានសមត្ថកិច្ច ដែលប្រព្រឹត្តអំពើពុករលួយ ការចាត់វិធានការប្រឆាំងនឹងជនអន្តោប្រវេសន៍ខុសច្បាប់ ការកោះហៅមន្ត្រីរដ្ឋាភិបាលចូលបំភ្លឺនៅសភាជាដើម ។

លោកបានបញ្ជាក់ថា "ដូចករណីសាំង គណបក្សប្រឆាំង ស្រែកតែប៉ុន្មានថ្ងៃ គឺឃើញថា តម្លៃសាំងចុះគ្រឹប តែបើអត់គណបក្សប្រឆាំងស្រែកមើលរដ្ឋាភិបាល ជិះសេះលែងដៃហើយ"។

លោកបានបន្តទៀតថា លោកមិនជាបានដឹងអំពីព័ត៌មានទាំងនេះស៊ីជ្រៅពេកទេ ប៉ុន្តែតាមកាសែត និងតាមកម្មវិធីព័ត៌មានដលែលាកហានមីលតាមតុកាហ្វេព្រឹកៗគឺឃើញថា រដ្ឋាភិបាលធ្វើជាបន្តបន្ទាប់ ហើយលោកក៏បានស្នើសុំឲ្យរដ្ឋាភិបាលនិងអាជ្ញាធរបន្តពិនិត្យ និង ដោះស្រាយបញ្ហាអសកម្មនៅក្នុងសង្គម ឲ្យបានច្រើនថែមទៀត ។

លោកបានបញ្ជាក់ថា " ខ្ញុំឃើញអាជ្ញាធរ ធ្វើសកម្មភាពមួយចំនួនហើយប៉ុន្តែអាបញ្ហាចំពោះមុខផ្សេងៗទៀតដូចជានៅដដែលដូចជា បញ្ហាសន្តិសុខ ចោរប្លន់អីនៅនឹងមុខៗ ឡានធំបើកចូលក្រុង កន្ទុយលេខអីពេញតែផ្លូវ។ល។"

លោក ឆាយ ម៉េង ជាប្រជាពលរដ្ឋកម្ពុជាអាយុ ៤០ ឆ្នាំមួយរូបដែលនៅម្តុំព្រែកឯង បានមានប្រសាសន៍ថារដ្ឋាភិបាល និងអាជ្ញាធរពិតជាបានចាត់វិធានការផ្សេងៗមែន តែបញ្ហាវាមានច្រើនណាស់ដែលមិនទាន់ដោះស្រាយហើយនៅតែទារលុយពីប្រជាពលរដ្ឋដដែលៗ ។

លោកបានបញ្ជាក់ថា "រឿងធ្វើអត្តសញ្ញាណប័ណ្ណ ប័ណ្ណគ្រួសារ សៀវភៅស្នាក់នៅអី គឺបើមិនអស់លុយទេធ្វើមិនចេញទេ ហើយជួនកាលសុទ្ធតែផ្តិតមេដៃថា អត់មានបង់លុយបង់កាក់ថែមទៀត "។

លោកបានបន្តទៀតថា អារឿងបង់លុយបង់កាក់នេះ គឺនៅមាន ប៉ុន្តែដូចជារៀងធូស្រាលជាងពីមុនខ្លះដែរ ដោយសារតែពីមុន គឺទារត្រង់ៗ តែម្តង ប៉ុន្តែនៅពេលបច្ចុប្បន្ននេះគាត់ប្រើពាក្យសុំ ហើយពាក្យសំដីសំដៅក៏មិនគំរោះគំរើយអីដូចជាពីមុនពេកដែរ។

នេះគឺជាការយល់ឃើញ របស់ប្រជាពលរដ្ឋសាមញ្ញ ប៉ុន្តែ បើតាមប្រសាសន៍របស់មន្ត្រីរាជការមួយរូបដែលសុំមិនបញ្ចេញអត្តសញ្ញាណ ក៏បានលើកឡើង នូវបញ្ហាដដែលៗនេះដែរ ប៉ុន្តែ លោកក៏បានចូលរួម បញ្ចេញយោបល់រាងស៊ីជម្រៅបន្តិចដែរ អំពីស្ថានភាព នៃការវិវត្តន៍នយោបាយចុងក្រោយនៅក្នុងប្រទេសកម្ពុជា ។

មន្ត្រីរាជការដែលមានវ័យ ៤៨ ឆ្នាំរូបនេះ បានមានប្រសាសន៍ថា តាមអ្វីដែលលោកបានចាំបានឮ ជាពិសេសគឺនៅក្នុងពេលបើកប្រជុំគណរដ្ឋមន្ត្រីអណត្តិទី៥កន្លងមករដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ គណបក្សកាន់អំណាច គឺ បានសន្យាច្រើន អំពីកំណែទម្រង់ស៊ីជម្រៅការព្រមានរឿងបក្សពួកនិយមនៅតាមក្រសួងមន្ទីរ ហាមធ្វើធំនៅកន្លែងណា យកប្រពន្ធយកកូនទៅធ្វើធំនៅកន្លែងនោះជាដើម ប៉ុន្តែបញ្ហាគឺវាដូចជានៅតែដដែល ។

លោកបានបន្តទៀតថា នៅពេលបច្ចុប្បន្ននេះ មន្ត្រីណាដែលស្និតនៅជាមួយនឹងមេមានឱកាស និង មានការងារធ្វើច្រើន អាចរស់នៅស្រួលតែអ្នកមិនសូវចេះស្និទ្ធ គឺបានត្រឹមតែម៉ារស់ៗ ស៊ីតែប្រាក់ខែ រដ្ឋរស់តាមតែព្រហ្មលិខិតប៉ុណ្ណោះ។

លោកបានបញ្ជាក់ថា "ប្រាជ្ញាកើតជាគឺបានត្រឹមតែបន្ទាប់បន្សំ ប៉ុន្តែបើបានប្រណិប័តន៍គួបផ្សំនឹងប្រពៃ។រៀនចប់ដូចគ្នា មានសមត្ថភាពក៏ដូចគ្នាតែយើងមិនចេះយកចិត្តប្រតិប័តន៍មេគឺចាញ់គេហើយ សម័យឥឡូវចំណុចនេះហើយគួរតែកែ"។

លោកបានបន្តទៀតថា នេះគឺជាបញ្ហានិងបិរយាកាសនៅកន្លែងធ្វើការរដ្ឋតាំងពីអណត្តិមុនៗមកម្ល៉េះ ហើយសង្ឃឹមថា រាជរដ្ឋាភិបាល នឹងដោះស្រាយចំណុចនេះនៅចុងអណត្តិទៅចុះ ពីព្រោះកំណែទម្រង់វាមិនងាយបានសំរេចទេ ។

លោក យ៉ង់ គីមអេង ប្រធានមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍនិងសន្តិភាព ដែលជាតំណាងអង្គការសង្គមស៊ីវិលមួយ បានជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជាខិតខំធ្វើកំណែទម្រង់

## កម្ពុជាកំពុងកសាងវប្បធម៌នៃការសន្ទនាគ្នា

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងជាអនុប្រធានគណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ថា ឥឡូវនេះប្រទេសកម្ពុជា កំពុងតែបង្កើតវប្បធម៌ នៃការសន្ទនា ដើម្បីកសាងប្រទេសជាតិឱ្យមានការរីកចម្រើននោះ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា វប្បធម៌នៃការសន្ទនានេះជាប្រធានបទ នៃការពិភាក្សាជាច្រើនលើកនៅក្នុងសភា រវាងគណបក្សប្រជាជន និង គណបក្សសង្គ្រោះជាតិ ជាពិសេសរវាងសម្តេចជាមួយនិងលោក សម រង្ស៊ី ។

តាមរយៈវប្បធម៌សន្ទនានេះ កម្ពុជានឹងមានតំណែងមួយ គឺប្រធានក្រុមសភាភាគតិច ដែលប្រធានក្រុមនេះ គឺនឹងមានឋានៈស្មើនឹងនាយករដ្ឋមន្ត្រី ប្រសិនបើក្រុមតំណាងរាស្ត្រនោះមានសម្លេង ២៥ ភាគរយ ៕

# ្សទាំងពីរធ្វើកំណែទម្រង់ពិតប្រាកដ



ា ២០១៤។ រូបភាព: សហការី

ឲ្យបានស៊ីជម្រៅ ដូចដែលបានសន្យា នៅក្នុងពេលប្រជុំគណៈរដ្ឋមន្ត្រីដំបូង កាលពីឆ្នាំ២០១៣ ហើយជាពិសេស គឺ ឲ្យគណបក្សពីរ ដែលមានអសនៈ នៅក្នុងសភា គឺគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិខិតខំស្វែងរកដំណោះស្រាយ លើកិច្ចព្រមព្រៀងនយោបាយ ដែលមានឲ្យបានឆាប់បើមិនដូច្នេះទេ កម្ពុជាអាចនឹងរស់នៅក្នុងសម័យអន្តរកាលបន្តថែមមួយឆ្នាំទៀត ។

លោកបាន មានប្រសាសន៍ថា ស្ថានភាពនៅក្នុងប្រទេសកម្ពុជា វាហាក់ដូចជា នៅក្នុងស្ថានភាពមួយស្ថិតនៅក្នុងអន្តរកាលមួយ ទៅអន្តរកាលមួយទៀត ប្រសិនបើមិនមានការធ្វើកំណែទម្រង់ឲ្យស៊ីជម្រៅ ដូចដែលរដ្ឋាភិបាលបានសន្យា ហើយគណបក្សទាំងពីរ មិនអនុវត្តទៅតាមកិច្ចព្រមព្រៀងនយោបាយ ឲ្យចប់ទេនោះ។

លោកបានបញ្ជាក់ថា "ស្ថានភាពនៅកម្ពុជា គឺជួនធ្វើឲ្យយើងសប្បាយចិត្ត ហើយជួនក៏ធ្វើឲ្យយើងខកចិត្តទៅវិញ។ ខ្ញុំថា ប្រសិនបើកិច្ចព្រមព្រៀងនយោបាយ មានតែនៅលើក្រដាស ហើយមិនព្រមខិតខំដោះស្រាយឲ្យចប់នៅក្នុងឆ្នាំនេះទេ ឆ្នាំថ្មីនឹងនៅតែជួបបញ្ហាដដែល ហើយកម្ពុជា ក៏ស្ថិតនៅក្នុងសម័យ អន្តរកាលទៀតហើយ"។

លោក កៅ ពឿន ប្រធានសមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា បានមានប្រសាសន៍ថា សភាពការណ៍នៅក្នុងប្រទេស នាដំណាក់កាលចុងក្រោយនេះគឺហាក់ដូចជាមានចំណុចវិជ្ជមានខ្លះ។

លោកបាន មានប្រសាសន៍ថា គណបក្សទាំងពីរ ចេះធ្វើការជាមួយគ្នា ចេះពិភាក្សាគ្នា មានការតាមដាននូវការអនុវត្ត របស់រាជរដ្ឋាភិបាលពីសភា នៅតាមគណកម្មការនីមួយៗ ហើយលទ្ធផល គឺចេះតែមានជាបន្តបន្ទាប់ដែរ ទោះបីជាវាមានតិចតួចៗក៏ដោយចុះ។ ប៉ុន្តែ នៅក្នុងនាមជាសង្គមស៊ីវិលមួយរូប ខ្ញុំចង់ឲ្យមានវប្បធម៌នៃការជជែកគ្នាបែបនេះ ឲ្យបានច្រើនថែមទៀត ដោយមិនយកកត្តាផលប្រយោជន៍ក្រុមធ្វើជាប្រធានបទ ។

នេះគឺជាចំណុចវិជ្ជមាន ប៉ុន្តែក្រៅពីចំណុចដែលវិជ្ជមាននេះ លោក កៅ ពឿន ក៏បានមើលឃើញនូវចំណុចអវិជ្ជមានជាច្រើន ដែលនៅក្នុងនោះ គឺមានដូចជា ក្តីរំពឹងដែលយើងចង់បាន គណកម្មការជាតិរៀបចំការបោះឆ្នោតដែលឯករាជ្យ។ ពួកយើង ដូចជាមានកាអស់សង្ឃឹមមែនទែនជុំវិញសភាពការនៃការវិវត្តន៍ថ្មីៗរបស់គណកម្មការការជាតិរៀបចំការបោះឆ្នោតហ្នឹង ។

លោកបានបន្តទៀតថា នេះគឺជាសភាពការ ជុំវិញការវិវដ្តផ្នែកនយោបាយចុងក្រោយ ខណៈដែលផ្នែកសង្គមវិញ លោកបានមើលឃើញថាគឺហាក់ដូចជា មិនមានការកែប្រែអ្វីសោះនៅក្នុងអណត្តិទី៥នេះ ។

លោកបានបញ្ជាក់ថា "យើងឃើញថា វប្បធម៌និទណ្ឌភាព គឺដូចជានៅដដែល ដូចជាមានការចាប់ពលរដ្ឋនៅបឹងកក់ ការចាប់ព្រះសង្ឃ ប្រព័ន្ធតុលាការ វប្បធម៌នៃការដឹកនាំមិនស្របតាមច្បាប់នោះ គឺនៅតែមានបន្តទៀតពោលគឺថាអ្វីដែលដើរខុសនោះ គឺនៅតែបន្ត ហើយគាត់មិនយកច្បាប់ជាធំសោះ"។

លោកបានបញ្ជាក់ថា "អ្វីៗ គឺដូចជាមិនមានការកែប្រែសោះ ដូចជាករណីកិច្ចព្រមព្រៀងនយោបាយ ពីមុនមាននាយករដ្ឋមន្ត្រីពីរ បោះឆ្នោតជាកញ្ចប់ ហើយឥឡូវនេះ គឺមានតំណែង ប្រធានក្រុមតំណាងរាស្ត្រភាគតិចនៅក្នុងសភា មានឋានៈស្មើនឹងនាយករដ្ឋមន្ត្រីដែលទាំងអស់នេះដូចជាមិនមានចែងក្នុងច្បាប់សោះ។

លោកបានបន្តទៀតថា មកដល់ពេលនេះគន្លាតរវាងអ្នកមាននិងអ្នកក្រ គឺកាន់តែខ្ពស់ទៅៗ ហើយជាក់ស្តែងឥឡូវនេះមានកំណើនប្រជាជនដែលកំពុងតែស្ថិតនៅក្នុងសភាពងាយរងគ្រោះ ដោយសារតែយើង មើលឃើញអំពីការកើនឡើងជាបន្តបន្ទាប់នៃក្រុមមនុស្សងាយរងគ្រោះ នេះដោយសារធនធានធម្មជាតិ កាន់តែសឹករិចរិលទៅៗ ហើយបរិយាកាសការងារនៅប្រឈមមុខ នឹងកង្វះខាតសុវត្ថិភាព ចំណីអាហារខ្វះសុវត្ថិភាព មានគីមី ។ល។

**ដោយអរិយបុត្រ**

## ម្ចាស់ជំនួយប្រកាសផ្តល់ជំនួយដល់កម្ពុជាជាបន្តបន្ទាប់

ក្រោយពេលកម្ពុជាមានស្ថេរភាពនយោបាយ ម្ចាស់ជំនួយធំៗនៅកម្ពុជាបានប្រកាសផ្តល់ជំនួយហិរញ្ញវត្ថុដល់កម្ពុជាជាបន្តបន្ទាប់ ។

រាប់តួរលេខត្រួសៗ ពីការសន្យារបស់ម្ចាស់ជំនួយកាលពីចុងខែ វិច្ឆិកា ដល់ដើមខែ ធ្នូ ឆ្នាំ២០១៤ នេះ កម្ពុជាបានទទួលការសន្យាគិតជាទឹកប្រាក់សរុបប្រមាណជា ២.៨៦០លានដុល្លារ ។

នៅក្នុងអំឡុងពេលនោះ ម្ចាស់ជំនួយដែលបានសន្យាជួយផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុដល់កម្ពុជា នៅក្នុងអំឡុងចន្លោះពីឆ្នាំ ២០១៤ ដល់ឆ្នាំ២០១៨នេះធំជាងគេនោះ គឺសហភាពអឺរុប បន្ទាប់មកគឺ ធនាគារអភិវឌ្ឍអាស៊ី និង ប្រព័ន្ធនៃអង្គការសហប្រជាជាតិ ។

សហភាពអឺរ៉ុប បានប្រកាសកាលពីថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៤ ថាខ្លួនបានត្រៀម ថវិការសម្រាប់ជួយដល់កម្ពុជា លើវិស័យអាទិភាពមួយចំនួន ដែលមានទឹកប្រាក់សរុបប្រមាណជា ១,៤ ពាន់លានយូរ៉ូ ឬប្រហាក់ប្រហែលនឹង ១,៨ ពាន់លានដុល្លារ ។

សម្រាប់ធនាគារអភិវឌ្ឍអាស៊ីវិញ គឺបានអះអាងថា នៅក្នុងអំឡុងពេលនេះគឺបានសន្យាផ្តល់ប្រាក់កម្ចីដល់កម្ពុជាប្រមាណជា ៨០០ លានដុល្លារ។ រីឯអង្គការសហប្រជាជាតិវិញនោះពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ គឺ បណ្តាទីភ្នាក់ងារ នៃអង្គការសហប្រជាជាតិទាំងអស់នៅកម្ពុជា មានគម្រោងធ្វើសកម្មភាពជាអាទិភាពរបស់ពួកគេជួយដល់កម្ពុជា ដែលមានទឹកប្រាក់ប្រមាណជា២៦៤ លានដុល្លារ ដោយនៅក្នុងនោះមូលនិធិអង្គការសហប្រជាជាតិផ្ទាល់មានប្រមាណជា ៥៣ លានដុល្លារ ប្រាក់កម្ចីប្រមាណជា ៣៤ លានដុល្លារ និង ត្រូវស្វែងរកបន្ថែម១៧៧ លានដុល្លារ៕

# លោកឧបដ្ឋាកយ៉ូហាន ម៉ារី ផាន បូរី ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ



លោក ផាន បូរីទទួលព្រះពរពីលោកអភិបាល។ រូបភាព: សម្បត្តិ

ក្បួនដង្ហែដែលមានបូជាចារ្យជាង ៥០អង្គអមដោយបទចម្រៀង បានធ្វើដំណើរអមលោកយ៉ូហាន ម៉ារីផាន បូរីប្រៀបដូចជាក្បួនដង្ហែកូនកំលោះចូលរោងមង្គលដូច្នេះដែរ។ ពាក់អាវបំពង់សវែង សំម្បុរស្រអែម លោក ផាន បូរី ជាឧបដ្ឋាកត្រូវបានអ្នកពិធីការឲ្យអង្គុយនៅមុខអង្គពិធី រង់ចាំទទួលអគ្គសញ្ញាតែងតាំង ជាបូជាចារ្យកាតូលិក នៅចំពោះមុខព្រះសហគមន៍។

កម្មវិធីចេះតែបន្តទៅមុខ ដែលមានលោកអភិបាល ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ អូលីវីយេ ឆ្មឹត ហស្លេរជាប្រធាន ដោយមានការចូលរួមពីលោកអភិបាលចូលនិវត្តន៍ និង លោកអភិបាលនៃព្រះសហគមន៍ភូមិភាគកំពង់ចាម និងបាត់ដំបង។ បន្តិចក្រោយមកលោកឧបដ្ឋាកផាន បូរីត្រូវបានហៅឲ្យបង្ហាញខ្លួននៅចំពោះមុខព្រះសហគមន៍ទាំងមូល ដើម្បីទទួលពិធីនានាក្លាយជាបូជាចារ្យ ដែលមានដូចជាពិធីថ្វាយពាក្យសច្ចា ទទួលអាវមេអំបៅ និង ពិធីគ្រៀបដៃតែងតាំងជាបូជាចារ្យកាតូលិក។

លោកបូជាចារ្យផាន បូរី ឲ្យដឹងថា " ពេលក្បួនដង្ហែ ខ្ញុំភ័យផង សប្បាយផង ចង់យំបន្តិច ពេលចាប់ផ្តើមកម្មវិធី តែក៏រំភើប ព្រោះខ្ញុំបានត្រៀមខ្លួនជាង១០ឆ្នាំដើម្បីក្លាយជាបូជាចារ្យ។ នេះជាអំណោយទានពីព្រះជាម្ចាស់"។

លោកបូជាចារ្យថ្មី ផាន បូរី កើតនៅ ឆ្នាំ១៩៨០ នៅភូមិក្តុលលើ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ លោកជាកូនបង ស្ថិតក្នុងគ្រួសារគ្រីស្តបរិស័ទ និង ជាកសិករ ដែលមានប្អូនៗចំនួន ៤នាក់។

លោកបូជាចារ្យ បូរី បន្ថែមថា ការរស់នៅក្នុងទេវវិទ្យាល័យ បានធ្វើឲ្យគាត់យល់ច្បាស់អំពីជីវិតជាអ្នកបួស ។ លោកប្រាប់ថា "ការអប់រំនៅក្នុងទេវវិទ្យាល័យ ខ្ញុំទទួលចំណេះដឹងពីខាងក្នុង និង ខាងក្រៅ (ព្រះសហគមន៍) ជាពិសេស ការអធិដ្ឋានជារៀងរាល់ថ្ងៃ ការណែនាំខាងផ្លូវវិញ្ញាណរបស់លោកបូជាចារ្យម៉ារីយ៉ូ ដែលធ្វើឲ្យផ្លូវវិញ្ញាណរបស់ខ្ញុំរីកចម្រើន រហូតមក និង ការរស់នៅជាក្រុមក៏បានជួយខ្ញុំផងដែរ គឺគេរៀនពីខ្ញុំហើយខ្ញុំរៀនពីគេដែរ"។

លោកបូជាចារ្យរូបនេះបន្តថា ពិធីតែងតាំងបានលើកទឹកចិត្ត ដល់រូបគាត់ក្នុងការបន្តបេសកកម្ម នៃការសង្គ្រោះរបស់ព្រះយេស៊ូ។ ក្នុងបេសកកម្មថ្មីនេះលោកនិយាយថា "ខ្ញុំនឹងខំប្រឹងធ្វើការ ឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំ និង ខ្ញុំរស់នៅជាមួយគ្រីស្តបរិស័ទ តាមរបៀបសាមញ្ញធម្មតា ដោយខិតខំប្រកាសដំណឹងល្អ របស់ព្រះយេស៊ូគ្រីស្តទៅដល់បងប្អូនដែលមិនទាន់ស្គាល់"។ លោកបន្ថែមថា "ខ្ញុំគិតថាព្រះសហគមន៍ត្រូវការគង្វាលជាជនជាតិខ្មែរដើម្បីបន្តជួយព្រះសហគមន៍នៅស្រុកខ្មែរ ហេតុនេះខ្ញុំសូមអង្វរព្រះជាម្ចាស់ដើម្បីជួយបំភ្លឺយុវជនយុវនារីឲ្យចេះឆ្លើយតបយ៉ាងពិតប្រាកដ ដោយរួមដំណើរជាមួយព្រះយេស៊ូគ្រីស្ត ដោយថ្វាយខ្លួនទាំងស្រុងទៅព្រះអង្គជាបូជាចារ្យ ឬជាដូនជី"។

ព្រះសហគមន៍ កាតូលិកកម្ពុជា បានចាប់កំណើតឡើងក្នុងឆ្នាំ១៩៥៥។ ក្នុងរបបប្រល័យពូជសាសន៍ព្រះសហគមន៍ត្រូវបានបំផ្លាញស្ទើរតែទាំងស្រុង ទាំងហេដ្ឋារចនាសម្ព័ន្ធ អគារ ហើយ គ្រីស្តបរិស័ទ បូជាចារ្យ និង អ្នកបួសជាតិខ្មែរត្រូវបានសម្លាប់។

នាពេលបច្ចុប្បន្ននេះ ព្រះសហគមន៍កាតូលិកកម្ពុជា មានបូជាចារ្យជាជនជាតិខ្មែរ ចំនួន៧រូបប៉ុណ្ណោះ ដោយរួមបញ្ចូលលោកបូជាចារ្យផាន បូរី និងលោកបូជាចារ្យមួង រស់ផង កំពុងបម្រើការងារ នៅតាមព្រះសហគមន៍កាតូលិកទាំងបីភូមិភាគគឺ ភ្នំពេញ កំពង់ចាម និង បាត់ដំបង។

លោកបូជាចារ្យ សេរ៉ាល់ រ៉ូសាំង បានឡើងថ្លែងសក្ខីកម្ម អំពីលោកបូជាចារ្យបូរីយ៉ាងនេះថា លោកបូរីជាយុវជនដែលមានចិត្តតស៊ូ ចិត្តសុភាពរាបសារ អត់ធ្មត់ក្នុងការសិក្សា យកចិត្តទុកដាក់កសាងសន្តិភាព និង លើកទឹកចិត្តគេផង បំពេញការងារដោយយកចិត្តទុកដាក់ និងចូលចិត្តអធិដ្ឋាន។ លោកជាមនុស្សដែលចេះជួយទុក្ខធុរៈអ្នកដទៃដោយចិត្តសទ្ធា ។

លោកបូជាចារ្យ សេរ៉ាល់ បន្ថែមថា មានកត្តាមួយចំនួនដែល បានជំរុញដល់បងប្រុសបូរីសម្រេចចិត្ត ជាបូជាចារ្យ គឺពិធីតែងតាំងលោកបូជាចារ្យខ្មែរចំនួន៤រូបនៅឆ្នាំ ២០០១ បានធ្វើឲ្យគាត់យល់ថា ជីវិតជាអ្នកបួស គឺមិនសម្រាប់តែជនបរទេស ប៉ុណ្ណោះទេ។ ហើយដោយមានការអធិដ្ឋានពីសំណាក់គ្រីស្តបរិស័ទ ដើម្បីជីវិតជាអ្នកបួស របស់យុវជន យុវនារីផងដែរ។ លោកបូជាចារ្យបន្ថែមថា "បងប្រុស បានទុកឲ្យព្រះជាម្ចាស់ណែនាំ ទោះបីគាត់មិនដឹងថាអនាគតទៅជាយ៉ាងណានោះទេ។"

ក្នុងអង្គពិធីនោះដែរ លោកអភិបាលអាន់តូនីសាមី ស៊ូសៃរាជ្យ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម មានប្រសាសន៍កោតសរសើរដល់ទឹកចិត្តឪពុកម្តាយរបស់បងប្រុស ដែលលោកប្រៀបធៀបទៅនឹងគង្វាលមួយដ៏ល្អរបស់កូនៗ ។ ទោះបីគ្រួសារនេះក្រីក្រតែបានចិញ្ចឹមឲ្យកូនៗ បានទទួលការសិក្សាគ្រប់គ្នា។

លោកអភិបាលបានបន្ថែមថា នៅពេលនេះ យើងសូមអរគុណព្រះជាម្ចាស់តាមរយៈការថ្វាយខ្លួនរបស់បងប្រុសបូរី។ ហើយយើងក៏អធិដ្ឋានដល់បងប្រុសបូរី ដើម្បីជាគំរូដ៏ល្អ និងអង្វរព្រះជាម្ចាស់ ដោយផ្ញើអំណោយទានដល់យុវជនយុវនារីរបស់យើង មិនគ្រាន់តែនៅទូទាំងប្រទេស។ លោកបន្ថែមថា "ការត្រាស់ហៅ មិនពឹងលើកំលាំងរបស់យើងប៉ុណ្ណោះទេ តែយើងពឹងលើព្រះជាម្ចាស់"។

អ្នកស្រីហ៊ិន សុខា ជាម្តាយរបស់លោកបូជាចារ្យបូរី បានមានប្រសាសន៍ថា "ខ្ញុំតែងតែអធិដ្ឋានឲ្យបូរីចេះឆ្លើយតបនឹងការត្រាស់ហៅ។ ខ្លាចបូរីងាកក្រោយ។ ពេលគិតរឿងនេះ ខ្ញុំតែងពិបាកចិត្ត ហើយតែងនិយាយជាមួយឪពុក(ប្តី) គឺយើងអធិដ្ឋាន អង្វរព្រះជាម្ចាស់ ព្រោះយើងស្រឡាញ់ជីវិតជាអ្នកបួស ចង់ឲ្យកូនម្នាក់បួសជាពិសេសកូនច្បង"។

អ្នកស្រីបន្ថែមថា ការថ្វាយកូនណាម្នាក់ទៅបម្រើព្រះសហគមន៍និងព្រះជាម្ចាស់ គឺជាអំណោយទានមួយដ៏វិសេស ដែលប្រៀបដូចជាដុំពេជ្រមួយគ្រាប់ឥតចឹង ដែលព្រះជាម្ចាស់បានប្រទាន មកដល់ក្រុមគ្រួសាររបស់អ្នកស្រី។

នៅថ្ងៃទី២២ វិច្ឆិកានេះ ក្តីស្រមៃរបស់អ្នកស្រី បានក្លាយជាការពិតក្រោយការតស៊ូសិក្សារបស់កូន អស់រយៈពេល ជាង១០ឆ្នាំមកនេះ។ លោកផាន បូរីបានតែងតាំងជាបូជាចារ្យកាតូលិក នៅព្រះសហគមន៍កំពង់ចាមក្រុង នៃភូមិភាគកំពង់ចាម ដែលមានគ្រីស្ត មកចូលរួមទាំងបីភូមិភាគប្រមាណជាង១០០០នាក់។

អ្នកស្រីសុខា បានផ្តាំកូនឲ្យខិតខំបន្ថែមទៀត ក្នុងកិច្ចការបម្រើព្រះសហគមន៍ដោយខិតខំអធិដ្ឋាន រិះគិតព្រះបន្ទូល ដោយពឹងលើព្រះជាម្ចាស់។ អ្នកស្រីសុខា បន្ថែមថា ប្រសិនបើយើងប្រើគំនិតផ្ទាល់ខ្លួននាំឲ្យព្រះសហគមន៍អត់ដំណើរការទៅមុខទេ តែបើយើងដើរជាមួយព្រះជាម្ចាស់ គឺកិច្ចការណាក៏នឹងអាចដោះស្រាយដោយងាយស្រួលដែរ។

មុនពេលបញ្ចប់ កម្មវិធីតែងតាំង លោកអភិបាល អាន់តូនីសាមី បានប្រកាសថា លោកបូជាចារ្យបូរី នឹងបំពេញបេសកកម្ម នៅក្នុងព្រះសហគមន៍កោះរការ ជាមួយលោកបូជាចារ្យ សេរ៉ាល់៕ **ដោយកញ្ញា**

# អ្នកស្រីដាំ ប្រាជ្ញាចង់បម្រើព្រះសហគមន៍រហូតអស់ជីវិត


អ្នកស្រីដាំប្រាជ្ញា ជាព្រឹទ្ធានៅព្រះសហគមន៍បាត់ដំបង។ រូបភាពៈ សុវណ្ណា

អ្នកស្រីដាំ ប្រាជ្ញា ជាយាយព្រឹទ្ធាម្នាក់នៅក្នុងព្រះសហគមន៍បាត់ដំបង។ កុមារនិងយុវជននៅក្នុងព្រះសហគមន៍កាតូលិក តែងហៅស្ត្រីចំណាស់ ៨០ ឆ្នាំនេះថា យាយប្រាជ្ញា។ មាឌធំទាប សម្បុរស្រអែម អ្នកស្រីប្រាជ្ញា បានចំណាយកាយចិត្តដើម្បីណែនាំយុវជនជំនាន់ក្រោយ អំពីរបៀបរៀបចំពិធីបុណ្យនានា និង ចូលរួមសកម្មភាពសង្គហៈក្នុងព្រះសហគមន៍ រួមជាមួយបងប្អូនវ័យស្របាលគាត់។

ក្នុងនាមជាព្រឹទ្ធាចារ្យម្នាក់ អ្នកស្រីបានខិតខំអស់ពីកំលាំងកាយចិត្តដើម្បីជួយកម្មវិធីផ្សេងៗ ក្នុងព្រះសហគមន៍តាមលទ្ធភាព ដែលអាចធ្វើទៅបានតាមព្រះអំណោយទាន របស់ព្រះជាម្ចាស់ ក្នុងតួនាទីជាអនុប្រធានសង្គហៈនៃព្រះសហគមន៍បាត់ដំបង។ កិច្ចការសង្គហៈមានដូចជា ចុះសួរសុខទុក្ខអ្នកក្រីក្រនិងអ្នកជំងឺ និង ជួយផ្តល់ជាសំភារៈខ្លះៗ ដល់ពួកគាត់។ អ្នកស្រីប្រាជ្ញា "ជំនឿបានជួយខ្ញុំឲ្យស្រឡាញ់ព្រះជាម្ចាស់ និង អ្នកដទៃ។ ពេលគេមានបញ្ហា ខ្ញុំអត់មានសំភារៈអីជួយគេទេ តែក៏អាចមានពាក្យសំដីលួងលោម និង លើកទឹកចិត្តគេដែរ។ យើងធ្វើតាមព្រះអំណោយទាន ពីព្រះជាម្ចាស់។ហើយខ្ញុំក៏អរព្រះគុណព្រះអង្គ ដែលឲ្យចិត្តខ្ញុំអត់ចេះប្រណែនថាគេធ្វើការដូចខ្ញុំ គេមានផ្ទះមានលុយជាង(ខ្ញុំ)អីអត់ទេ"។

ក្រៅពីការងារទាំងនេះ អ្នកស្រីក៏បានចងក្រងចម្រៀងចាស់ៗ ក្នុងសម័យមុនមហាសន្និបាត បុរីវ៉ាទីកង់ទី២ (ឆ្នាំ១៩៦៥) និង ចម្រៀងសម្រាយជាភាសាជាតិ មុនរបបប៉ុលពតជាដើម ដើម្បីទុកជាកេរ្តិ៍មរតកសម្រាប់ព្រះសហគមន៍កាតូលិក បាត់ដំបងជំនាន់ក្រោយ។

អ្នកស្រីដាំ ប្រាជ្ញា "ក្រោយពីសម័យសង្គ្រាម យើងសល់គ្រីស្តបរិស័ទមួយចំនួនធំដែរដូច្នេះយើងត្រូវអនុវត្តតាម(ពី)ដើមខ្លះដូចជា ធម៌ខ្លះពីបូរាណ យើងត្រូវតែឲ្យក្មេងចេះសូត្រអធិដ្ឋានតាមរបៀបបូរាណខ្លះដែរ។ ដូចនៅភ្នំពេញ អត់មានសូត្រទេ ដូចជាធម៌ឱព្រះនាងព្រហ្មចារី"។

នៅព្រះវិហារព្រះជាម្ចាស់ លើកព្រះនាងម៉ារីឡើងស្ថានបរមសុខដែលសព្វថ្ងៃប្រជាជន តែងហៅទីនោះថា ពេទ្យយាយជីស្ថិតនៅក្នុងទីក្រុងបាត់ដំបង ក្រោយពេលបញ្ចប់អភិបូជារៀងរាល់ថ្ងៃអាទិត្យគ្រីស្តបរិស័ទទាំងចាស់ក្មេង បាននាំគ្នាសូត្រធម៌ពីដើមដែលបានបន្សល់ទុក ដោយមនុស្សចាស់ជំនាន់មុន។

សព្វថ្ងៃ អ្នកស្រីដាំ ប្រាជ្ញា មានកូន៥នាក់ និង ចៅចំនួន១១នាក់ រីឯគ្រួសារអ្នកស្រីបានទទួលមរណភាពកាលពីប៉ុន្មានខែកន្លងទៅ។

រំលឹកពីជំនឿកូនៗ អ្នកស្រីហាក់ដូចជាពិបាកចិត្តបន្តិច ដោយពោលថា "កូនខ្ញុំមានអំណោយទានមិនដូចខ្ញុំទេ គេគិតប្រយោជន៍ផ្ទាល់ខ្លួនច្រើនគិតពីជីវភាព ព្រោះខ្ញុំអត់មានអីឲ្យគេទេ"។ទោះជាយ៉ាងនេះក្តី ស្ត្រីជាម្តាយរូបនេះ នៅតែដាស់តឿនកូនគ្រប់ពេលកុំឲ្យកូនភ្លេចជំនឿរបស់ខ្លួន។ អ្នកស្រីប្រាជ្ញាបន្តថា គាត់ទូរស័ព្ទរំលឹកកូនឲ្យអុជធូបឲ្យឪពុករាល់ថ្ងៃសៅរ៍ឬត្រូវចូលរួមអភិបូជា ត្រូវអធិដ្ឋាន។ អ្នកស្រីប្រាជ្ញា "ខ្ញុំធ្វើអស់ពីសមត្ថភាពជាម្តាយ។ ឃើញថា ពេលបុណ្យធំៗ ដូចជាចូលឆ្នាំ ភ្ជុំ និងតែងតាំងបូជាចារ្យអី ពួកគេមកទាំងអស់គ្នា។ ឥឡូវនេះ មានចៅៗ៤នាក់នៅជាមួយខ្ញុំ ខ្ញុំឲ្យវាទៅរៀនអប់រំជំនឿ ធ្វើសកម្មភាពព្រះសហគមន៍ខ្លះ"។

ទោះបីអ្នកស្រីវ័យចាស់ណាស់ទៅហើយក្តី ក៏អ្នកស្រីមិនដែលបោះបង់ចោលព្រះវិហារដែរ។ "ខ្ញុំត្រូវចូលនិវត្តន៍នៅអាយុ៦០ឆ្នាំ តែអត់ថយទេចង់តែធ្វើថែមទៀត។តែបើរឿងប្រើកម្លាំងថយហើយ។ ខ្ញុំតែងអង្វរព្រះជាម្ចាស់ថា ព្រះអង្គអើយ កូនចង់បម្រើព្រះសហគមន៍ លុះត្រាតែដាច់ខ្យល់លែងនិយាយកើតមើលអត់ឃើញតែម្តង" ៕

ដោយកល្យព្រឹក្ស

# មរណសាក្សីនាង ប្លង់ ឌីន


មរណសាក្សីនាង ប្លង់ ឌីន

នាងប្លង់ឌីនជាស្ត្រីបម្រើដែលរស់នៅក្នុងក្រុងលីយ៉ុង ប្រទេសបារាំង ដើម គ.ស ១៧៧។ ជាសម័យ រដ្ឋអំណាចធ្វើទុក្ខបុកម្នេញ យ៉ាងឃោរឃៅប្រឆាំងនឹងគ្រីស្តបរិស័ទនៅលីយ៉ុង និងវីយ៉ែន។គេចោទប្រកាន់គ្រីស្តបរិស័ទអំពីបទឧក្រិដ្ឋ ជាពិសេសគេចោទថាគ្រីស្តបរិស័ទ មិនថ្វាយបង្គំព្រះចៅអធិរាជ។ គេផ្តន្ទាទោសគ្រីស្តបរិស័ទដោយធ្វើទារុណកម្ម។ ការបៀតបៀននេះចាប់ផ្តើមយ៉ាងរហ័ស។

ក្នុងនោះមាននាងប្លង់ឌីន និងគ្រីស្តបរិស័ទជាច្រើនផងដែរ។ អស់អ្នកដែលទទួលស្គាល់ថាខ្លួនជាគ្រីស្តបរិស័ទ គឺនៅតែជាប់គុក តែអាជ្ញាធរមិនចោទប្រកាន់បន្ថែម ពីបទឧក្រិដ្ឋផ្សេងទៀតទេ។ រីឯអស់ អ្នកដែលក្បត់ជំនឿវិញ អាជ្ញាធរឃុំឃាំងគេតទៅទៀត តែចោទប្រកាន់បន្ថែមថាជាឃាតក និង ជាមនុស្ស មានកិរិយាអាក្រក់។ តាមរយៈនាងព្រះគ្រីស្តសម្តែង ឲ្យយើងដឹងថា "អ្វីៗដែលមនុស្សលោកចាត់ទុកថា ទន់ខ្សោយគួរឲ្យមាក់ងាយ និងគ្មានតម្លៃ តែព្រះជាម្ចាស់ចាត់ទុកថា ជាសេចក្តីរឹងប៉ឹង និង ថ្លៃថ្នូរទៅវិញ"។ មុនដំបូងគេទាំងអស់គ្នាគិតថា នាងប្លង់ឌីនមិនអាចប្រកាសជំនឿរបស់នាងដោយចិត្តក្លាហានបានទេ ព្រោះនាងមានកម្លាំងទន់ខ្សោយពេក តែនាងបែរជាចេះនិយាយដដែលៗថា៖ "ខ្ញុំជាគ្រីស្តបរិស័ទ។ យើងជាគ្រីស្តបរិស័ទមិនដែលប្រព្រឹត្តអំពើ អាក្រក់ទេ"។ ដោយពាក្យនេះ ទើបនាងមានកម្លាំងស្ងប់ចិត្តនិង បន្ថយការឈឺចាប់ផង។

គេយកនាង ទៅព្យួរទៅនឹងបង្គោល ឲ្យសត្វព្រៃហែកស៊ីសាច់ តែវាហាក់ដូចគេព្យួរនាងលើ ឈើឆ្កាងទៅវិញ។ គេឮនាងអធិដ្ឋាន ដោយសំឡេងខ្លាំងៗ ធ្វើឲ្យគេមានសេចក្តីក្លាហានកាន់តែខ្លាំងឡើងដែរ។ ហើយធ្វើឲ្យ ក្រុមមរណសាក្សីអ្នក ដែលបោះបង់ជំនឿភាគច្រើនមានសេចក្តីក្លាហានឡើងវិញ ពួកគេកើតសាជាថ្មី ពោរពេញដោយកម្លាំង។

បន្ទាប់មកគេវាយនាង គេដាក់នាង ឲ្យអង្គុយនៅលើកៅអីដែកដុតឲ្យក្រហម ហើយគេក៏ដាក់នាង ក្នុងសំណាញ់មួយ ឲ្យគោបាបុកនាងត្រវាត់ច្រើនលើកច្រើនសារ។ ក្នុងទុក្ខលំបាក នាងសន្ទនាជាមួយព្រះគ្រីស្តជានិច្ចក្នុងចិត្ត។ គេសម្លាប់នាងដោយអារក។ សូម្បីតែអ្នកកាន់សាសនាដទៃ ក៏ទទួលស្គាល់ថា នៅក្នុងស្រុករបស់គេ មិនដែលមានស្ត្រីណាម្នាក់ ស៊ូទ្រាំនឹងទារុណកម្មដ៏សែនឈឺចុកចាប់បានយូរដូច នាងប្លង់ឌីននេះទេ។ រីឯសពគ្រីស្ត បរិស័ទស្លាប់ដោយថប់ខ្យល់ក្នុងគុក គេបោះឲ្យឆ្កែហែកស៊ី៕

# លោកមួង រស់ ៖បូជាចារ្យជាអ្នកបម្រើដោយដាក់ខ្លួន


លោក មួង រស់ ទទួលព្រះពរពីលោកអភិបាល។ រូបថតៈ សម្បត្តិ

កាលពីថ្មីកន្លងទៅនេះ លោកឧបដ្ឋាកមួង រស់ ត្រូវបានតែងតាំងជាបូជាចារ្យមួយរូបទៀត នៅក្នុងភូមិភាគបាត់ដំបង ក្រោមអធិបតីភាពរបស់លោកអភិបាលទាំងបីភូមិភាគដោយមានការចូលរួម ពីគ្រីស្តបរិស័ទជាង ២០០០នាក់ មកពីគ្រប់តំបន់នៃប្រទេសកម្ពុជា។

ពាក់អាវមេអំបៅ លោកបូជាចារ្យថ្មីមួង រស់បានពោលថា ៖ "ខ្ញុំរំភើប ខ្ញុំសប្បាយពេញលក្ខណៈពិតមែន! ដែលនេះ ជាគោលបំណងរបស់ខ្ញុំជាយូរមកហើយ"។

លោកបូជាចារ្យមួង រស់ ជាកូនប្រុសច្បង ដែលមានបងប្អូន ៤នាក់ ដែលមានម្ដាយជាពុទ្ធបរិស័ទ មានស្រុកកំណើតនៅខេត្តកំពង់ធំ។ ក្នុងរយៈពេលជាង១០ឆ្នាំដែលលោករស់នៅក្នុងទេវវិទ្យាល័យ លោកបានរកឃើញជីវិតថ្មី គឺភាពជាបូជាចារ្យ។ លោកបានឲ្យដឹងថា "សម្រាប់ខ្ញុំជីវិតជាបូជាចារ្យមានន័យថា ខ្ញុំត្រូវបន្ទាបខ្លួនអស់ពីសមត្ថភាព ធ្វើតាមព្រះបន្ទូលរបស់ព្រះយេស៊ូ លោកអភិបាល បងប្អូន និង អស់អ្នកដែលសហការជាមួយបូជាចារ្យដែរ"។ លោកបានឲ្យដឹងទៀតថា ក្នុងបេសកកម្មនេះ លោកនឹងបន្ទាបខ្លួន អស់ពីសមត្ថភាពដើម្បីបម្រើព្រះសហគមន៍ ដោយរួមជាមួយអស់អ្នកគង្វាលនានា និងបងប្អូនគ្រីស្តបរិស័ទ។ លោកបន្ថែមថា"ខ្ញុំនឹងអធិដ្ឋានទៅព្រះជាម្ចាស់និងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបម្រើព្រះសហគមន៍។

លោកបូជាចារ្យមួង រស់ ត្រូវបានចាត់ឲ្យបំពេញកិច្ចការងារ នៅព្រះសហគមន៍កាតូលិកស្ទឹង ក្នុងខេត្តបាត់ដំបង និង ទទួលខុសត្រូវក្រុមត្រាស់ហៅរបស់យុវជន នៃព្រះសហគមន៍ភូមិភាគបាត់ដំបងទាំងមូល។

ជាមួយមុខងារថ្មីនិងការចាត់តាំងពីលោកអភិបាល លោកមួង រស់ បានសន្យានឹងខិតខំណែនាំ ឲ្យយុវជនយល់ដឹងបន្ថែម អំពីការត្រាស់ហៅ។ លោករស់ "ខ្ញុំនឹងខិតខំរកមធ្យោបាយអស់ពីសមត្ថភាព ដើម្បីសហការជាផ្លូវមួយ ជាមួយបងស្រី និង លោកឪពុក(ដោយ)យើងបង្កើតកម្មវិធីបែបណាដើម្បីឲ្យយុវជនអាចរិះគិតជាមួយគ្នាអំពីរបៀប នៃការត្រាស់ហៅរបស់ព្រះជាម្ចាស់។មានវិធីណាដែលអាច (ឲ្យយុវជន) ឆ្លើយជាមួយព្រះជាម្ចាស់។ ខ្ញុំមិនទាន់ដឹងថាត្រូវធ្វើយ៉ាងណាទេ តែខ្ញុំនឹងអង្គុយគិត និង រៀនពីភ្នំពេញដែរ គឺរៀនអំពីរបៀបនៃក្រុមអេម៉ាណូអែល សាម៉ូអែល ដែលបានធ្វើ។នេះជាមធ្យោបាយមួយ ហើយខ្ញុំនឹងរកវិធីបន្ថែមទៀត ពីប្រទេសក្រៅផងដែរ"។

លោកបូជាចារ្យថ្មីបន្ថែមថា ចំពោះគាត់ អ្វីដែលជំរុញឲ្យគាត់ក្លាយជាបូជាចារ្យ គឺបានមកពីការលើកទឹកចិត្តរបស់លោកបូជាចារ្យ និង លោកអភិបាល និង ក្រុមគ្រួសាររបស់លោកផ្ទាល់។ លោកមួង រស់ "បើសិនតែម្នាក់ឯង ខ្ញុំទៅអត់បាន។ ខ្ញុំត្រូវការអ្នកលើកទឹកចិត្ត គឺលោកបូជាចារ្យបងប្រុស បងស្រី និង គ្រីស្តបរិស័ទអធិដ្ឋានសម្រាប់ខ្ញុំ និង គ្រួសារផងដែរគាំទ្រខ្ញុំ"។ លោកបន្ថែមថា ការសំខាន់បំផុតសម្រាប់រូបលោក គឺ ការទុកពេលវេលា ដើម្បីអធិដ្ឋានទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ ផ្តល់កម្លាំងដើម្បីបម្រើ ដើម្បីឆ្លើយថា បាទខ្ញុំចង់បម្រើព្រះសហគមន៍ក្នុងមុខងារ តួនាទី និងឋានៈជាបូជាចារ្យនេះ។

ក្នុងធម្មទេសនា របស់លោកអភិបាល គីគេ ហ្វីការេដូ ជាអភិបាលប្រចាំភូមិភាគបាត់ដំបង បានមានប្រសាសន៍ក្នុងពិធីតែងតាំង លោកបូជាចារ្យ មួង រស់កាលពីថ្ងៃទី ៦ ធ្នូនេះថា ៖ នេះគឺជាអំណោយទានយ៉ាងពិសេសពីព្រះជាម្ចាស់ ដែលប្រទានលោកបូជាចារ្យ យ៉ូសែប មួងរស់ជាបូជាចារ្យនៅប្រទេសកម្ពុជាម្នាក់ទៀត។លោកអភិបាលគីគេ បានបន្តឲ្យដឹងថា ៖ ក្នុងពេលនេះ លោកសូមឲ្យ លោកបូជាចារ្យថ្មី គឺលោក មួង រស់ សូមឲ្យនៅស្និទ្ធស្នាល ជាមួយព្រះជាម្ចាស់ ថែរក្សា និង ជួយអ្នកដែលគ្មានសេចក្តីសង្ឃឹម ។ ចេះចែករំលែកសេចក្តីស្រលាញ់អំណរសប្បាយ និង ជំនឿឲ្យអ្នកដទៃ។ ជាពិសេស សូមឲ្យលោកបូជាចារ្យថ្មីនេះធ្វើតាមសកម្មភាពព្រះយេស៊ូអស់មួយជីវិតត្រូវមានគំនិតវែងឆ្ងាយទូលំទូលាយ សម្រាប់ព្រះសហគមន៍។ចំណុចចុងក្រោយដែលលោកអភិបាលគីគេផ្តល់ឲ្យនោះគឺ ត្រូវទៅកន្លែងដែលគេមិនស្គាល់ ព្រះសហគមន៍ដើម្បីប្រកាសដំណឹងល្អអំពីព្រះយេស៊ូ។

ក្នុងឱកាសនោះដែរ លោកអភិបាល អូលីវីយេ បានមានប្រសាសន៍លើកទឹកចិត្តបន្ថែម ដល់លោកបូជាចារ្យថ្មីទាំងពីរដែលបានតែងតាំងក្នុងឆ្នាំថ្មីនេះថា"ខ្ញុំសូមជូនពរដល់រស់និងបូរី ឲ្យមានសុភមង្គលយ៉ាងពិតប្រាកដ។ សុភមង្គលពិតប្រាកដសម្រាប់បូជាចារ្យ គឺមានឱកាសដើម្បីប្រគល់ជីវិតដែលមកពីព្រះជាម្ចាស់តាមអត្តសញ្ញានានា បម្រើបងប្អូន និងសង្គមផង និង ជាពិសេសគឺធ្វើដំណើរយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូដោយសារយើងបានផ្ញើជីវិតទៅព្រះយេស៊ូ ។ ដូច្នេះជាបូជាចារ្យត្រូវធ្វើដូចម្តេចដើម្បីធ្វើតាមព្រះហឫទ័យ របស់ព្រះជាម្ចាស់គ្រប់ពេលវេលា"។

ជាមួយគ្នានេះ លោកអភិបាល អូលីវីយេ បានបន្តថា ពិធីតែងតាំងនេះ គឺយើងអរព្រះគុណព្រះជាម្ចាស់ដែលមានលោកបូជាចារ្យថ្មី ២ នាក់បន្ថែម ហើយកម្មវិធីនេះ គឺឲ្យយើងយល់ថាការអប់រំយុវជនឲ្យក្លាយជាបូជាចារ្យត្រូវចំណាយពេលយូរជាមូលហេតុដែលយើងត្រូវការ១០ឆ្នាំ។ យើងដឹងថា ព្រះសហគមន៍របស់យើងតូច ហើយទើបតែរស់ឡើងវិញ ប្រហែលជាង២០ឆ្នាំ ដូច្នេះយើងមិនត្រូវប្រញាប់ប្រញាល់ពេកទេ។លោកបន្ថែមថា យើងត្រូវចូលទៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់។ ហើយយើងមានអំណរសប្បាយ ពិសេសសម្រាប់ព្រះសហគមន៍កម្ពុជាទាំងមូល ជាពិសេសភូមិភាគកំពង់ចាម និងបាត់ដំបងដែលនេះជាលើកទី១ ដែលមានបូជាចារ្យតែងតាំងនៅភូមិភាគរបស់ពួកគេ។

នៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្នមានក្រុមបព្វជិត សាសនទូត បងប្រុស ដែលបម្រើព្រះសហគមន៍ ជាជនបរទេស ដែលមានចំនួនជាង ១៥០នាក់ ក្នុងនោះមាន បូជាចារ្យជាតិខ្មែរតែ៧នាក់ប៉ុណ្ណោះ ដោយរួមបញ្ចូលទាំងលោកបូជាចារ្យថ្មី ២ អង្គ គឺលោកផាន បូរី និងលោកមួង រស់។ នៅឆ្នាំក្រោយនេះព្រះសហគមន៍នឹងមាន លោក ឧបដ្ឋាកសុខ ណា ទទួលការតែងតាំង ជាបូជាចារ្យនៅក្នុងព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ក្នុងខែមិថុនា ខាងមុខនេះ៕

## សេចក្តីជូនដំណឹង

ព្រះសហគមន៍ កាតូលិកប៉ោយប៉ែត មានកិត្តិយស សូមជំរាបជូនដំណឹង ដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់ឲ្យបានជ្រាបថា ព្រះសហគមន៍ប៉ោយប៉ែតនិងរៀបចំពិធីអរព្រះគុណព្រះជាម្ចាស់និងពិធីសម្ពោធព្រះវិហារថ្មី ដែលមានឈ្មោះថា ព្រះវិហារសន្តីម៉ារីម៉ាដាឡាប៉ោយប៉ែត នៅថ្ងៃអាទិត្យទី០៤ ខែមករា ឆ្នាំ២០១៥ វេលាម៉ោង ៣រសៀលខាងមុខនេះ។ ទំនាក់ទំនងដើម្បីចូលរួម៖ លោកបូ. ពូទី រ៉ាយ៉ាត់ (០១២ ២១៤ ៩៣០), បងស្រី ហាស៊ូម៉ាទី (០៩២ ៧៧៥ ០៣១), លោកសេង សុភាព(០១២ ៦១៧ ៥៦២)។

# យុវជនកាតូលិករិះគិតអំពីព្រះជាម្ចាស់ជាប្រភពនៃជីវិត



លោក ហ្វ្រង់ស្វ័រ អប់រំជំនឿដល់យុវជន-យុវនារី។ រូបថតៈ ៉រារី

កាលពីពេលថ្មីៗនេះគណៈកម្មការព្រះសហគមន៍កាតូលិកក្នុងខេត្តកំពង់ចាម បានរៀបចំសិក្ខាសាលាស្ដីអំពីព្រះជាម្ចាស់ជាប្រភពនៃជីវិតទាំងអស់សម្រាប់យុវជនចំនួន ៨០ ដើម្បីឲ្យយុវជន ស្គាល់ព្រះជាម្ចាស់កាន់តែច្រើនជាងមុន នៅព្រះសហគមន៍ភូមិថ្មីក្នុងខេត្តកំពង់ចាម។

លោក ហ្វ្រង់ស័រ អេមេល្យដាល ជាបូជាចារ្យទទួលខុសត្រូវ ព្រះសហគមន៍ភូមិថ្មីឲ្យដឹងថា៖ សិក្ខាសាលារៀបចំឡើង គឺយើងចង់ដាស់តឿន និង ឲ្យយុវជនស្គាល់ព្រះជាម្ចាស់កាន់តែច្បាស់ ហើយនិងកាន់តែជិតស្និទ្ធជាមួយព្រះអង្គ និងឲ្យពួកគាត់យល់ដឹងបន្ថែមអំពីស្នាព្រះហស្ដរបស់ព្រះជាម្ចាស់ដែលបានបង្កើតអ្វីៗសព្វសារពើនៅលើផែនដីនេះផងដែរ។ លោកបន្ថែមថា ម៉្យាងទៀតយើងចង់ប្រមូលយុវជនឲ្យមកជួបជុំគ្នា សប្បាយជាមួយគ្នា និង ស្គាល់គ្នាទៅវិញទៅមកផងដែរ។

យុវនារី ឌន នីតា មកព្រះសហគមន៍កាតូលិកចម្លាក់បានឲ្យដឹងថា៖ អស់រយៈពេល៣ថ្ងៃដែលគាត់បានរៀនពីព្រះជាម្ចាស់ គាត់ចាប់អារម្មណ៍ចំណុចមួយជាងគេគឺថា "តើអំពើអាក្រក់កើតចេញមកពីណា"។ ក្រោយពីបានទទួលការពន្យល់ពីលោកឪពុករួចមក គាត់ចាប់ផ្ដើមយល់បានច្រើន ពីព្រះ-ជាម្ចាស់ និង ជិតស្និតជាមួយព្រះអង្គជាងមុន។ នីតាបន្តថា គាត់សប្បាយចិត្តមែនទែន ដែលបានជួបមិត្តភ័ក្ដច្រើន និង បានស្គាល់មិត្តបានច្រើនជាងមុន លើសពីនេះទៅទៀតគឺគាត់បានទទួលបទពិសោធន៍ថ្មីៗ ពីបងប្អូនទាំងនោះផងដែរ។

យុវជន ឃន ចាន់ណា ជាយុវជនម្នាក់មកពីព្រះសហគមន៍រលៀកបានឲ្យដឹងដែរថា៖ អ្វីដែលគាត់ទទួលបានពីសិក្ខាសាលានេះមានដូចជា បទពិ-សោធក្នុងការធ្វើការងារជាក្រុមទទួលបានបទពិសោធជាច្រើនទាក់ទងនឹងជំនឿ និងជាពិសេសគឺគាត់បានយល់ច្រើនពីអត្ថន័យព្រះបន្ទូលព្រះជាម្ចាស់ ហើយនិងព្រះហឫទ័យរបស់ព្រះអង្គមកយើងទាំងអស់គ្នាតាមរយៈបងប្អូននៅជុំវិញយើងផងដែរ។

ក្នុងសិក្ខាសាលានេះ យុវជនសិក្សាទៅលើ ព្រះគម្ពីរកំណើតពិភពលោក និង អត្ថបទលោក បាទីមេ ណែនាំដោយលោក បូជាចារ្យ ហ្វ្រង់ស័រ អេមេល្យដាល បងស្រី ប៊ុនថារី ថេរេសា និងគណៈកម្មការព្រះសហ-គមន៍កំពង់ចាមក្រុង និងភូមិថ្មី។

សិក្ខាសាលានេះបានធ្វើឡើងក្នុងឱកាសបុណ្យអំទូកសំពះព្រះខែរយៈពេល៣ថ្ងៃ ចាប់ពីព្រឹកថ្ងៃទី ៥-៧ វិច្ឆិកា មានអ្នកចូលរួម សុទ្ធសឹងជាយុវជន ដែលមកពីព្រះសហគមន៍កាតូលិកចម្លាក់ ភូមិថ្មី រលៀក និងកំពង់ចាមក្រុង៕

**ដោយហេង ៉រារី**

# ជាង១០ឆ្នាំព្រះសហគមន៍ក្រចេះមានអ្នករៀបការពាគូ

ក្នុងរយៈពេលជាង១០ឆ្នាំមកនេះ ក្រោយពេលមានបូជាចារ្យទទួលខុសត្រូវច្បាស់លាស់ ព្រះសហគមន៍កាតូ-លិកក្រចេះ ស្ថិតនៅភូមិទី១ ឃុំករកណ្ដាល ស្រុកក្រចេះ ខេត្តក្រចេះ បានរៀបចំអាពាហ៍ពិពាហ៍ ជូនគ្រីស្ត-បរិស័ទប្រមាណ៣គូហើយ។

លោកអ៊ីវ៉ាន់ កាំប៉ាញ៉ាជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍កា-តូលិកក្រចេះផ្ទាល់ និង ជាបូជាចារ្យណែនាំវគ្គអប់រំអាពាហ៍ពិពាហ៍ បានឲ្យដឹងថា ៖ រហូតមកដល់ពេលនេះ គូស្រករ ដែលបានទទួលវគ្គអប់រំមុនពេលរៀបការនេះ មានចំនួន៣ គូហើយ គឺពីឆ្នាំមុន មានមួយគូ និងថ្មីៗនេះមានពីរគូទៀត។

លោកបូជាចារ្យរូបនេះបន្តថា ព្រះសហគមន៍កាតូលិកយើងបានរៀបចំវគ្គអប់រំគូស្រករនេះឡើងគឺក្នុងគោលបំណងចង់ឲ្យគូស្រករទាំងអស់ដែលនឹងត្រៀមចូលរោងការ ហើយនឹងក្លាយជាជីវិតជាប្ដី-ប្រពន្ធឆាប់ៗ យល់ដឹងឲ្យច្បាស់ពីការរស់នៅជាជីវិតមានគ្រួសារ និង ភ្ជាប់ជាមួយជីវិតជាគ្រីស្តបរិ-ស័ទផងដែរ ដើម្បីឲ្យពួកគេចេះត្រៀមខ្លួន មានទំនួលខុសត្រូវខ្ពស់សម្រាប់គ្រួសាររបស់គេនិងនាំឲ្យគ្រួសាររបស់ពួកគេដើរជាមួយគ្នា ប្រកបដោយសេចក្ដីសុខសាន្ត និង សុភមង្គល។ គាត់បានបន្តទៀតថា ក្នុងមេរៀននេះមានដូចជា៖ អប់រំអំពីលក្ខណៈជាគ្រួ-សារ អប់រំអំពីពិធីបុណ្យផ្សេងៗ ក្នុងព្រះសហគមន៍ ដើម្បីឲ្យគេយល់ច្បាស់ពីអត្ថន័យនីមួយៗនៃពិធីបុណ្យរបស់ព្រះសហគមន៍អប់រំពីអត្តសញ្ញា និងឲ្យពួកគេរៀនពីទុក្ខលំបាកសុភមង្គលក្នុងគ្រួសារ ពីបទពិសោធន៍ របស់ប្ដី-ប្រពន្ធចាស់ៗពីមុនមក។

ព្រះសហគមន៍កាតូលិក ក្រចេះចាប់ផ្ដើមកើតឡើងតាំងពីឆ្នាំ ១៨៨២ មកម្ល៉េះ រហូតមកដល់ពេលនេះ មានរយៈពេលជាង១៣២ឆ្នាំហើយ។

ក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ព្រះសហគមន៍កាតូលិកក៏ដូចជាប្រជាជនខ្មែរ និង សាសនានានានៅក្នុងប្រទេសកម្ពុជាត្រូវបានបំផ្លាញ និងសាសនិក ត្រូវបានសម្លាប់ស្ទើរទាំងស្រុង។ ក្រោយពីរបបនេះដួលរលំ គ្រីស្តបរិស័ទបានចាប់ផ្ដើមមករស់នៅសារជាថ្មី លើទឹកដីក្រចេះនេះម្ដងទៀត។

លោកបូជាចារ្យអ៊ីវ៉ាន់ បានបញ្ជាក់ថា ចុងឆ្នាំ២០០១-២០០៥ គឺមានលោកបូជាចារ្យ សាឡាសាណូ យ៉ូហានយេស៊ូ មកមើលការខុសត្រូវលើព្រះសហគមន៍នេះ ដែលមានតែបងប្អូនគ្រីស្តបរិស័ទវៀតណាមពីដើម ប្រមាណជា៤គ្រួសារប៉ុណ្ណោះ មិនទាន់មានគ្រីស្តបរិស័ទខ្មែរនៅឡើយទេ ។ ហើយចាប់តាំងពីឆ្នាំ ២០០៧ មកដល់បច្ចុប្បន្ននេះ មានគ្រីស្តបរិស័ទសរុបមានចំនួន ១២នាក់ មានខ្មែរចំនួន៧នាក់៕

**ដោយហេង ៉រារី**



រូបថតៈ លីហៀង

# លោកអភិបាលជំរុញឲ្យគ្រីស្តបរិស័ទបង្ហាញធម៌មេត្តាករុណាបន្ថែមទៀត


លោកអភិបាលបកស្រាយព្រះគម្ពីរនៅព្រះវិហារថ្មី។ រូបថតៈ សុធីរិទ្ធិ

ក្នុងពិធី សម្ពោធព្រះវិហារសន្ត យ៉ូសែប នៃព្រះសហគមន៍ស្អាង ស្ថិតក្នុងមណ្ឌលសកម្មភាពទន្លេបាសាក់ ក្នុងខេត្តកណ្តាល លោកអភិបាលភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតហាស្លែរ បានមានប្រសាសន៍ថា "ប្រសិនបើយើងចូលព្រះវិហារស្អាត តែចិត្តរបស់យើងមិនស្អាតបរិសុទ្ធទេនោះ សក្ខីភាពរបស់យើងក៏គ្មានន័យដែរ"។

លោកអភិបាលបន្តថា ដូចនេះ យើងត្រូវយល់ថា ព្រះជាម្ចាស់បានអញ្ជើញយើង ឲ្យកសាងព្រះសហគមន៍របស់ព្រះអង្គ ហើយយើងទាំងអស់គ្នាជាព្រះកាយព្រះគ្រីស្ត គឺទុកឲ្យព្រះយេស៊ូ យាងចូលក្នុងខ្លួនយើង ដោយមានជំនឿរឹងមាំ ព្យាយាមអធិដ្ឋាន ដើម្បីទៅជាតំណាងព្រះយេស៊ូ ទៅកាន់អ្នកដទៃ"។លោកបានបន្ថែមថា ព្រះជាម្ចាស់ទន្ទឹងរង់ចាំស្នាដៃរបស់យើងម្នាក់ៗ តាមរយៈការបង្ហាញនិង ចែករំលែក ធម៌មេត្តាករុណាចំពោះ អ្នកដទៃ។ ដូចនេះសូមអនុវត្តន៍ក្នុងសេចក្តីស្រឡាញ់ សម្រាប់អ្នកជំងឺអ្នកដែលអស់សង្ឃឹម អ្នកខ្វះខាតក្នុងជីវិត។

ក្នុងកម្មវិធីនោះ មានគ្រីស្តបរស័ទជិតឆ្ងាយ ចូលរួមប្រមាណជាង៦០០ នាក់នាថ្ងៃទី ១៦ វិច្ឆិកា ២០១៤ ។ លោកអភិបាលអូលីវីយេ បានមានប្រសាសន៍កោតសរសើរ ដល់បងប្អូនគ្រីស្តបរិស័ទ នៃព្រះសហគមន៍នេះផងដែរ ដែលបានចូលរួមជាកំលាំង និងថវិកា ដើម្បីសម្រេចបាននូវព្រះវិហារមួយ សម្រាប់លើកតម្កើងព្រះជាម្ចាស់។ លោកបន្តថា នេះជាអំណរសប្បាយដែលយើងបានរួមគ្នាកសាងព្រះសហគមន៍។ លោកអភិបាលបន្ថែមថា ព្រះវិហារគឺជាសញ្ញាសម្គាល់មួយដល់ពុទ្ធបរិស័ទ ដែលរស់នៅទីនេះ ដោយព្រះវិហារ ជាកន្លែងដែលយើងថ្វាយអភិបូជា ទទួលអគ្គសញ្ញានានា និងម្យ៉ាងទៀត ជាកន្លែងដែលយើងទទួលកម្លាំង ដើម្បីប្រកាសពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដល់អ្នកដទៃ។

តាមប្រសាសន៍របស់លោក ស៊ុន ឡេងហៅរ៉ាំង ជាប្រធាន នៃក្រុមគណៈកម្មការព្រះសហគមន៍នេះ បានឲ្យដឹងថាព្រះវិហារនេះត្រូវការចំណាយអស់ទឹកប្រាក់សរុប ២៣២០០ ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះបានមកពីគ្រីស្តបរិស័ទក្រៅប្រទេស និង មកពីគ្រីស្តបរិស័ទ ក្នុងព្រះសហគមន៍នេះ និង មកពីព្រះសហគមន៍ក្នុងស្រុកជួយគាំទ្រ។

ព្រះសហគមន៍ស្អាង បានកកើតមានឡើងកាល ពីឆ្នាំ១៩៩៣ ដោយគ្រីស្តបរិស័ទ ចំនួន៨១គ្រួសារ មកពីកោះគរ ខេត្តកណ្តាល។ បច្ចុប្បន្នព្រះសហគមន៍នេះ មានគ្រីស្តបរិស័ទប្រមាណ ១៣៥គ្រួសារ ដោយមានសកម្មភាពជួយអ្នកក្រីក្រ អធិដ្ឋានសួរសុខទុក្ខអ្នកជំងឺ និង សកម្មភាពបង្ហាញធម៌មេត្តាករុណា ជាច្រើនទៀត។

**ដោយដាលីស**

# ក្មេងៗសប្បាយជាមួយគំនិតច្នៃប្រឌិតរបស់យុវជន

កូនក្មេងប្រមាណជា ៤០នាក់ រត់លេងក្នុងបរិវេណ ព្រះសហគមន៍កាតូលិកត្រែងត្រយឹង ដែលមានទីតាំងស្ថិនៅក្នុងភូមិ២ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ពួកគេបានសប្បាយ ជាមួយឧបករណ៍កីឡាសម្រាប់កុមារហាត់ប្រាណ ដែលធ្វើដោយក្រុមយុវជន នៃព្រះសហគមន៍ព្រះសហគមន៍ កាលពីដើមខែវិច្ឆិកា ២០១៤នេះ។

លោក លេង ហុង ដែលជាគណៈកម្មាការអប់រំ បានឲ្យដឹងថា ដោយសារយើងមានឈើចាស់ៗច្រើនដែលលោកបូជាចារ្យ អ៊ុន សុន យកមកឲ្យ។ និង មានសំភារៈមួយចំនួនទុកចោល ដូច្នេះយើងបានគិត ជាមួយក្រុមយុវជន ដើម្បីបង្កើតឧបករណ៍កីឡា និង ឧបករណ៍សម្រាប់កុមារលេង ក្រៅពីនោះ យើងបានធ្វើតារាងបាល់ទះមួយទៀតផងដែរ។

ឧបករណ៍កីឡាទាំងអស់នោះមាន ដូចជា ដែកទីបសម្រាប់ដើរ តារាងបាល់ទះ បារដីខ្សាច់ ទោងឈើជាដើម។

លោកបានបន្តថា ការសម្រេចចិត្តធ្វើសកម្មភាពនេះ មានគោលបំណង ៣យ៉ាងគឺទី១៖ ព្រះសហគមន៍ចង់ផ្តល់កន្លែងមួយសុវត្ថិភាព ដើម្បីឲ្យកុមារមានទីកន្លែងលេង ព្រោះកន្លងមក មានកុមារគ្រោះថ្នាក់ដោយសារលង់ទឹក ម៉ូតូ ឬ ឡានបុក ជាដើម ។ល។ទី២៖ ដើម្បីឲ្យកូនក្មេងយល់ថាព្រះសហគមន៍ជាកន្លែងដែលមានអំណរសប្បាយ និង មានសេចក្តីស្រលាញ់ចំពោះពួកគេ។ និងទី៣ជួយសម្រួលបន្ទុកឪពុកម្តាយរបស់ពួកគេដែលរវល់រកស៊ីចិញ្ចឹមជីវិត និង កាត់បន្ថយពីភាពខ្វល់ខ្វាយ អំពីសុវត្ថិភាពរបស់កូន។

យុវជនសុខ ចន្ទី ដែលជាប្រធានក្រុមយុវជន នៃព្រះសហគមន៍កាតូលិកត្រែងត្រយឹង បាននិយាយថា ៖


ក្មេងៗកំពុងលេងសប្បាយជាមួយសម្មិតិផលច្នៃប្រឌិត។ រូបថតៈ លេង ហុង

" ខ្ញុំមិនហត់ ក្នុងការធ្វើឧបករណ៍សម្រាប់ក្មេងលេងទេ! តែខ្ញុំពិតជាអំណរសប្បាយ នៅពេលដែលខ្ញុំឃើញពួកគេរត់លេង និង លេងឧបករណ៍ ដែលក្រុមយើងបានច្នៃប្រឌិតយ៉ាងសប្បាយរីករាយបែបនេះ"។

សព្វថ្ងៃ ក្រៅពីការលេងកំសាន្តជាមួយឧបករណ៍ទាំងនេះ ព្រះសហគមន៍ក៏បានរៀបចំកម្មវិធី បង្រៀនភាសាខ្មែរ អង់គ្លេស ដល់ក្មេងទាំងឡាយ ដែលបានមកលេងនៅទីនោះផងដែរ៕

**ដោយហុង មង្គល**

# យុវជនក្រុមវ៉ាំងសង់ដឺប៉ូលជួយសម្អាតមន្ទីរពេទ្យ និងសួរសុខទុក្ខអ្នកជំងឺ



រូបថតអនុស្សាវរីយ៍របស់ក្រុមវ៉ាំងសង់ដឺប៉ូលនៅមន្ទីរពេទ្រព្រះកុសមៈ។ សហការី

យុវជន ក្រុមវ៉ាំងសង់ដឺប៉ូល ប្រមាណជា២០នាក់ មកពីមណ្ឌលនិស្សិតកាតូលិកកម្ពុជា បានរៀបចំកម្មវិធីជួយសម្អាត មន្ទីរពេទ្យព្រះកុសមៈ នាទីក្រុងភ្នំពេញ និងចុះសួរសុខទុក្ខអ្នកជំងឺ នៅមន្ទីរពេទ្យនោះផងដែរ កាលពីថ្ងៃទី១៥វិច្ឆិកាកន្លងទៅនេះ។

លោកណុប ណៃន ជានិស្សិតឆ្នាំទី៣ សិក្សាជំនាញសេដ្ឋកិច្ច ដែលជាប្រធានក្រុមវ៉ាំងសង់ដឺប៉ូលនេះបានឲ្យដឹងថា សកម្មភាពនៅក្នុងថ្ងៃនេះគឺ យើងជាយុវជន ចង់បង្ហាញអំពីអារម្មណ៍ និង ទឹកចិត្តស្រលាញ់របស់យុវជននៃក្រុមរបស់យើង ចំពោះអ្នកជំងឺ តាមរយៈ ការសួរសុខទុក្ខពួកគាត់ ដោយមានផ្ដល់គ្រឿង បរិភោគបន្តិចបន្តួច ហើយចូលរួមបោសជូតសំអាតបន្ទប់សម្រាកសម្រាប់អ្នកជំងឺនៅក្នុងមន្ទីរពេទ្យព្រះកុសមៈនេះ។ លោកបានបន្តថា យុវជនទាំងអស់ជាយុវជនកាតូលិកស្ម័គ្រចិត្ត នៃសមាគមសន្តវ៉ាំងសង់ដឺប៉ូលកម្ពុជា និង ជានិស្សិតដែលកំពុងសិក្សា នៅតាមមហាវិទ្យាល័យនានាក្នុងទីក្រុងភ្នំពេញហើយកំពុងស្នាក់នៅក្នុងមណ្ឌលនិស្សិត ព្រះសហគមន៍កាតូលិក។

លោកណុប ណៃមឲ្យដឹងទៀតថា "ទោះបីយើងមានការអស់កម្លាំងបន្តិចបន្តួចក៏ពិតមែន តែយើងទទួលបាននូវភាពសាមគ្គីនៅក្នុងក្រុម យ៉ាងស្វាហាប់ ដើម្បីបំពេញកាតព្វកិច្ចរបស់ក្រុម និង មានការទទួលបាននូវភាពរាក់ទាក់ដោយស្នាមញញឹម ពីសាច់ញាតិអ្នកជំងឺផងដែរ។ ហើយកិច្ចការមនុស្សធម៌នេះវាបានផ្ដល់សារៈសំខាន់ណាស់សម្រាប់យុវជន ដូចជាការបង្ហាត់បង្រៀនពួកគាត់ឲ្យធ្វើកាងារជាក្រុម និង ចេះចែករំលែកនូវសេចក្ដីស្រលាញ់របស់ខ្លួន ទៅឲ្យមនុស្សជុំវិញខ្លួន ហើយក្រុមយើងខ្ញុំនឹងសង្ឃឹមថាយើងនឹងមានឱកាសក្នុងការបង្កើតកម្មវិធីនេះ នៅមន្ទីរពេទ្យម្ដងទៀត"។

អ្នកជំងឺម្នាក់នៅមន្ទីរពេទ្យ បាននិយាយាថា ៖ គាត់មានអារម្មណ៍សប្បាយរីករាយណាស់ ដោយបានឃើញយុវជន ចូលរួមចុះសួរសុខទុក្ខអ្នកជំងឺនៅមន្ទីរពេទ្យនេះ។ អ្នកស្រីសូមកោតសរសើរចំពោះ សកម្មភាពយុវជនដែលធ្វើទៅ ដោយស្មារតីស្វាហាប់ ទោះបីជាពួកគាត់មកពីគ្រួសារក្រីក្រនៅតាមខេត្តផ្សេងៗពីគ្នា តែពួកគាត់បានចែករំលែក ទាំងពេលវេលា និង កំលាំងក្នុងការចូលរួមសង្គមយើង។

វី ពិសិទ្ធ អាយុ២១ឆ្នាំ ជានិស្សិតមកពីមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកបានឲ្យដឹងថា គាត់បានចូលរួមក្នុងសកម្មភាពក្រុមវ៉ាំងសង់ដឺប៉ូលប្រមាណជិត១០ឆ្នាំមកហើយ តាំងពីគាត់រៀនថ្នាក់ទី៧ ក្នុងខេត្តកំពង់ចាម។ ពិសិទ្ធិ បាននិយាយថា "ដំបូងចេះតែចូលតាមគេទៅ តែក្រោយមកឃើញលោកឪពុក បងស្រីគាត់មកពីប្រទេសផ្សេងៗ តែគាត់ជួយប្រទេសយើង ខ្ញុំក៏មានចិត្តស្រឡាញ់សកម្មភាពសង្គមដូចគាត់។ ការងារដែលខ្ញុំធ្វើមាន កក់សក់ឲ្យក្មេងៗ ជួយធ្វើអនាម័យភូមិ ជួយជួសជុលនិងធ្វើផ្ទះចុះទៅតាមមន្ទីរពេទ្យសួរសុខទុក្ខអ្នកជំងឺ ចែកអាហារពេលយប់ ដល់អ្នករស់នៅតាមចិញ្ចើមថ្នល់អីអស់ហ្នឹង"។

ពិសិទ្ធគិតថា ការលះបង់ពេលវេលាដើម្បីជួយសង្គម ជាកិច្ចការដែលគ្រីស្ដបរិស័ទត្រូវធ្វើ ហើយជាការងារដែលគាត់ពេញចិត្ត និង ស្រឡាញ់ទៀតផង។ ពិសិទ្ធិ "ទោះបីជាអត់ត្រូវជំនាញ តែខ្ញុំគិតថាជាទឹកចិត្តរបស់យើង។ ពេលខ្លះកញ្ចប់ថវិកាយើងអត់គ្រប់គ្រាន់ សមាជិកក្រុមរៃអង្គាសគ្នាជួយដល់ក្រុមក៏មាន"។ ពិសិទ្ធ បានបន្តថា ទោះបីគាត់រៀនចប់ពីមណ្ឌលនិស្សិតទៅក៏ដោយ ក៏គាត់មានឆន្ទៈមួយគឺចង់បន្តជួយដល់អ្នកក្រីក្រតាមរយៈក្រុមនេះដដែល។

សមាគមសន្តវ៉ាំងសង់ដឺប៉ូល ជាក្រុមមួយ របស់ព្រះសហគមន៍កាតូលិក ឈរលើស្មារតីបម្រើអ្នកក្រីក្រ ដោយយកចិត្តទុកដាក់ បង្ហាញធម៌មេត្តាករុណា របស់ព្រះជាម្ចាស់ទៅដល់បងប្អូនឯទៀតៗតាមគំរូដ៏ប្រសើររបស់សន្តវ៉ាំងសង់ដឺប៉ូល។ កិច្ចការរបស់ក្រុមនេះមាន ផ្ដល់អាហាររូបករណ៍ដល់កុមារក្រីក្រ កម្មវិធីសួរសុខទុក្ខអ្នកជំងឺឬអ្នកក្រីក្រ ផ្ដល់បង្គន់អនាម័យដល់អ្នកភូមិមួយចំនួនដែលខ្វះខាត ជួសជុល និង សង់ផ្ទះដល់ស្ត្រីមេម៉ាយ និង ក្រីក្រ ចែកអាហារដល់អ្នកអត់ឃ្លានជាដើម។

សព្វថ្ងៃ សមាគមនេះមានចំនួន ២៤ ក្រុម ដែលមានសមាជិកជាង ៤០០នាក់ភាគច្រើនជាយុវជន មានទីតាំងនៅតាមបណ្ដាខេត្ត និង ព្រះសហគមន៍កាតូលិកនានាក្នុងប្រទេសកម្ពុជា ។

**ដោយសុខ យឹម**


**មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈជនពិការ បន្ទាយព្រាប**

សូមជម្រាបដល់បងប្អូនពិការដែលមានបំណងចង់សិក្សាជំនាញខ្លីឲ្យបានជ្រាបថា យើងខ្ញុំមានទទួលជនពិការដើម្បីរៀនជំនាញដោយឥតបង់ថ្លៃដូចខាងក្រោម ៖

១. ផ្នែកកសិកម្ម
២. ផ្នែកកាត់ដេរសំលៀលបំពាក់
៣. ធ្វើស្បែកជើង
៤. ផ្នែកជួសជុលគ្រឿងអេឡិចត្រូនិច
៥. ជួសជុលម៉ូតូ
៦. ជួសជួលទូរស័ព្ទ

ចាប់ផ្ដើមទទួលពាក្យចូលរៀនពីថ្ងៃផ្សាយដំណឹងនេះតទៅរហូតដល់ខែមករា ឆ្នាំ២០១៥។

ទំនាក់ទំនងបន្ថែម ទូរស័ព្ទលេខ៖
០១២ ៧២០ ៦២៦ ឬ ០១៥ ៧២០ ៦២៦

BANTEAY PRIEB
CENTER FOR THE DISABLED



លោកតា រ៉ាបាំង

## មរណសាក្សីកម្ពុជា៖
# ប្រវត្តិរូបរបស់លោករ៉ាបាំង

(តពីលេខមុន) ...ពេលនោះដោយមាន លោកពួកគេជាជំនួយការ លោកបន្តការចិញ្ចឹមមាន់ ក្នុងគម្រោងនាំអ្នកភូមិ ឲ្យប្រកបមុខរបរនេះ ។ ហេតុនេះហើយបានជា ប្រជាជននៅភូមិក្តុលលើ ដាក់រហស្សនាមលោកឪពុកថា "លោកតា ពងមាន់"!

លោកក៏ធ្លាប់ បំរើព្រះសហគមន៍មួយទៀត នៅត្រើយម្ខាងចំការកៅស៊ូបឹងកេត។ នៅទីនោះមានគ្រីស្តបរិស័ទវៀតណាម ដែលធ្វើការនៅចំការកៅស៊ូ ហើយក៏មានគ្រីស្តបរិស័ទបារាំងដែលជាបុគ្គលិកក្រុមហ៊ុនកៅស៊ូដែរ។ ដូច្នេះហើយ រាល់ថ្ងៃអាទិត្យលោកត្រូវបកស្រាយអត្ថន័យ ព្រះគម្ពីរជាបីភាសា គឺ ខ្មែរ វៀតណាម និងបារាំង!

**សង្គ្រាម៖**

ប៉ុន្តែប៉ុន្មានខែក្រោយមក នៅឆ្នាំ ១៩៧០ សង្គ្រាមផ្ទុះឡើង បណ្តាលឲ្យសកម្មភាពរបស់ព្រះសហគមន៍ត្រូវបន្ថយដែរ។ រហូតដល់ខែ ឧសភា ពួកខ្មែរក្រហមរួមជាមួយពួកវៀតកុងចូលលុកលុយនៅតំបន់ក្រូចឆ្មារ ។ ជនជាតិបារាំងដែលធ្វើការនៅទីនោះរត់ភៀសខ្លួនទាំងអស់គ្នា ដូច្នេះលោករ៉ាបាំង បានអញ្ជើញទៅក្រុងកំពង់ចាម ដើម្បីសួរយោបល់ ពីលោក អង់ ដ្រេ ឡឺស៊ូអែហ្វ (Andre Lesouef) ជាអភិបាល ព្រះសហគមន៍កាតូលិក។

ក្រោយពីបានត្រិះរិះពិចារណា ជាមួយលោកអភិបាលរួចមក លោកក៏សម្រេចចិត្ត ត្រឡប់ទៅជួបគ្រីស្តបរិស័ទរបស់លោកវិញ ដើម្បីសួរយោបល់របស់ពួកគេ។ ដំបូងលោក រ៉ាបាំង គិតថា នឹងចាកចេញទៅតាមពួកគេដែរ តែក្រោយមកលោកសម្រេចចិត្តនៅជាមួយគ្រីស្តបរិស័ទវិញ តាមសំណើរបស់ពួកគេ។ លោកផ្ញើសារមួយទៅលោកឪពុក ហ្វ្រង់ស័រ ប៉ុងសូដ៍ (Francois Ponchaud) ដែលរង់ចាំលោកឯត្រើយម្ខាង។កាលនោះលោក ប៉ុងសូដ៍ កំពុងជម្លៀសគ្រីស្តបរិស័ទវៀតណាម ឲ្យចេញពីក្រូចឆ្មារ ទៅប្រទេសវៀតណាមវិញ តាមកាណូតដែលលោកបានជួល ។ ក្នុងសំបុត្រមានសរសេរថា៖ "គ្រីស្តបរិស័ទចង់ឲ្យខ្ញុំនៅជាមួយពួកគេ សូមឲ្យបាន សម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គចុះ"។ ពាក្យទាំងនេះគឺជាលិខិតចុងក្រោយរបស់លោក។

បីបួនថ្ងៃក្រោយមក ពួកខ្មែរក្រហមបានបោះទីតាំងនៅជិតភូមិក្តុល។ នៅខែមិថុនា យន្តហោះចម្ការកៅស៊ូមួយថតឃើញលោក រ៉ាបាំង នៅក្នុងផ្ទះ ឯពួកវៀតកុងនៅក្នុងទីធ្លា។ ដោយយន្តហោះនេះ បើកកាត់ម្តងហើយម្តងទៀត បណ្តាលឲ្យពួកអ្នកបដិវត្តន៍ចាប់លោក យកទៅសួរចម្លើយអស់មួយអាទិត្យ។

ដើមខែសីហា ក្រោយពីបំផ្លាញសំណង់អគាររបស់ព្រះសហគមន៍ជាច្រើនកន្លែងនៅប្រទេសកម្ពុជា ដែលគេសង្ស័យថា ជាកន្លែងបោះជំរំរបស់ពួកវៀតកុង ពេលនោះយន្តហោះទ័ពអាកាសរបស់រដ្ឋាភិបាលព្រៃនគរ ក៏ទំលាក់គ្រាប់បែកលើព្រះវិហារសាលារៀន និង ផ្ទះរបស់បងស្រីនៅក្តុល។ ការទំលាក់គ្រាប់បែក លើកទីពីរនេះធ្វើឲ្យអគារទាំងនោះខ្ទេចទាំងស្រុង។ លោកបូជាចារ្យទាំងពីរក៏បានប្តូរកន្លែងមករស់នៅក្នុងខ្ទមស្លឹកធំមួយ ដែលនៅជិតព្រះវិហារ ហើយលោកក៏បន្តចិញ្ចឹមមាន់ដើម្បីចិញ្ចឹមជីវិត។ ទោះជាពួកខ្មែរក្រហម និង វៀតកុងត្រួតត្រាលើតំបន់នោះក៏ដោយ ក៏លោករ៉ាបាំង និង លោកឡេវ៉ាន់ឌុង នៅតែបំពេញកិច្ចការរបស់គាត់បាន ដោយមិនសូវជាលំបាកប៉ុន្មានទេ។ អភិបូជាធ្វើនៅក្នុងផ្ទះ ដោយប្រើស្រាអភិបូជាធ្វើមកពីទំពាំងបាយជូរព្រៃ ឬ ស្រាសំប៉ាញ ដែលផ្ញើមកជាសំងាត់ដោយបូជាចារ្យម្នាក់ ដាក់បង្កប់ក្នុងដើមចេកដឹកដោយរទេះគោចូលមក។ ជួនកាលកម្មាភិបាលវៀតកុងអនុញ្ញាតឲ្យលោកបូជាចារ្យទាំងពីរ ជិះកង់ នៅក្នុងតំបន់បាន។លោកឡេវ៉ាន់ឌុងក៏បានទទួលការអនុញ្ញាតឲ្យទៅសួរសុខទុក្ខគ្រីស្តបរិស័ទនៅឯឆ្លូង និង ក្រចេះបានបួនប្រាំដងដែរ។ ក្នុងខែកញ្ញាឆ្នាំ១៩៧០ បព្វជិតវៀតណាម ស្រុកស្នួលបីនាក់ដែលបានភៀសខ្លួន មកនៅក្រុងក្រចេះនោះក៏មកនៅភូមិក្តុលលើជាមួយបូជាចារ្យទាំងពីរដែរ។ ក្នុងអំឡុងពេលពីរឆ្នាំ កម្មាភិបាលភូមិអនុញ្ញាតឲ្យជូនដំបង្រៀនក្មេងៗ នៅក្នុងសាលាស្លឹកមួយ។ លោករ៉ាបាំង ធ្លាប់មានប្រសាសន៍ទៅគ្រីស្តបរិស័ទថា៖ "ខ្ញុំសុខចិត្តនៅជាមួយបងប្អូនរហូត ទោះបីជានៅសល់តែបងប្អូនម្នាក់ក៏ដោយ"។

នាដើមឆ្នាំ១៩៧២ ស្ថានការណ៍នយោបាយចុះដុនដាបយ៉ាងខ្លាំង ។ កម្មាភិបាលភូមិទាមទារ អត្ថបទគម្ពីរសម្រាប់សូត្រក្នុងអភិបូជា និង ធម្មទេសនា របស់លោកមកពិនិត្យមើលជាមុនហើយហាមមិនឲ្យជូនដំបង្រៀនអំពីគ្រីស្តសាសនាតទៅទៀតឡើយ ។

លោកប្រឹងប្រែង ទៅសួរសុខទុក្ខជាពិសេស អ្នកជំងឺ និង អ្នកក្រីក្រ។

(នៅមានត)



## សម្តេចប៉ាប៖ អំពើរំលូតកូនស្មើនឹងបាបកម្មប្រឆាំងនឹងព្រះជាម្ចាស់

សម្តេចប៉ាប ហ្វ្រង់ ស៊ីស្កូជា ថ្មីម្តងទៀត បានមានប្រសាសន៍ថា សកម្មភាពនិងអំពើរំលូតកូនរបស់មនុស្ស គឺស្មើនឹង បាបកម្មដែលគ្រីស្តបរិស័ទបានធ្វើទៅលើព្រះជាម្ចាស់។

ទីភ្នាក់ងារព័ត៌មានកាតូលិក បានឲ្យដឹងថា ប្រាប់រឿងបាបកម្មនេះទៅក្រុមគ្រូពេទ្យកាតូលិក មួយក្រុម ចំនួន ៤០០០នាក់ដែលបានជួប សម្តេចកាលពីថ្ងៃទី១៥ ខែ វិច្ឆិកា នៅវិមាន យ៉ូហាន ទី៦ នាបុរីវ៉ាទីកង់។

សម្តេចប៉ាប ហ្វ្រង់ ស៊ីស្កូ បានមានប្រសាសន៍ថា ការធ្វើសកម្មភាពលេងជាមួយនឹងជីវិតតាមផ្លូវ ដូចជាការរំលូតកូននិងការអនុញ្ញាតឲ្យមនុស្សសម្លាប់ខ្លួនដោយគ្មានការឈឺចាប់ គឺជាអំពើបាបកម្ម ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបន្តទៀតថា ជីវិតមនុស្សម្នាក់ៗ សូម្បីតែទើបបង្កកំណើត គឺមានតម្លៃធំធេងណាស់ ជីវិតគឺជាវត្ថុពិសិដ្ឋ ដែលយើងត្រូវតែថែរក្សាឲ្យខានតែបាន ទោះបីជានៅពេលនេះ ពិភពលោកកំពុងតែរស់នៅក្នុងពេលវេលាមួយដែលយើងអាចនិយាយបានថា ជាពេលវេលាពិសោធជាមួយនឹងជីវិតនេះក៏ដោយ ៕

## វ៉ាទីកង់ធ្វើសន្និសីទនិយាយអំពីភាសានៃក្តីស្រលាញ់ថ្មី

ភាសានៃក្តីស្រលាញ់ថ្មី ត្រូវបានទីភ្នាក់ងារព័ត៌មានកាតូលិករាយការណ៍ព័ត៌មានថា នឹងក្លាយជាប្រធានបទដែលនឹងត្រូវលើកយកមក ពិភាក្សាគ្នានៅក្នុងសន្និសីទមួយ ដែលរៀបចំឡើងនៅក្នុងបុរីវ៉ាទីកង់ ដើម្បីជួយឲ្យបុរស និង នារី ឲ្យមានទំនាក់ទំនងឈានទៅរៀបការ ជាមួយនឹងការយល់ដឹងអំពីទំនាក់ទំនង នៅក្នុងស្ថាប័នគ្រួសាររបស់មនុស្ស ។

ប្រភពដដែលបានឲ្យដឹងថា នៅក្នុងសន្និសីទ ពីថ្ងៃទី១៧-១៩ វិច្ឆិកា នេះ អ្នកចូលរួមនឹងពិភាក្សាគ្នាដើម្បីស្វែងរកនូវភាសាថ្មី ដែលជាគំនិតច្នៃប្រឌិត បង្កើតនូវភាសារថ្មីសម្រាប់និយាយទៅកាន់ មនុស្សគ្រប់រូបអំពីក្តីស្រលាញ់ ។

សន្និសិទនេះ រៀបចំឡើងដោយ លោកស្រី ហេឡេន អាល់វ៉ារ៉េ ដែលជាសាស្ត្រាចារ្យច្បាប់នៅសកលវិទ្យាល័យ ចច ម៉ាសុន និង ជាអ្នកជំនាញខាងផ្នែកទំនាក់ទំនង។ សន្និសីទនេះបានទទួលការគាំទ្រ ពីបណ្តាស្ថាប័នជាច្រើននៅបុរីវ៉ាទីកង់ ដែលរួមមាន ដូចជា ក្រសួងគោលលទ្ធិនៃជំនឿ ក្រុមប្រឹក្សានៃព្រះសហគមន៍ សម្រាប់គ្រួសារ ក្រុមប្រឹក្សាសន្ទនាអន្តរសាសនា ។ល។



លោក ដួង សារ៉ង់ អ្នកទទួលខុសត្រូវមណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិក

### សប្ដាហ៍ទី ១ ក្នុងរដូវអបអរសាទរ ព្រះគ្រីស្ដយាងមក

*ត្រូវនឹងថ្ងៃអាទិត្យ ទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៤ (ម.ក ១៣, ៣៣-៣៧)*

ព្រះគ្រីស្ដយាងមកវិញ ប្រៀបដូចជាបុរសម្នាក់ ដែលចេញពីផ្ទះ ហើយចែកការងារឲ្យអ្នកបម្រើធ្វើ ឲ្យគេមើលការខុសត្រូវ និង បង្គាប់ឲ្យគេប្រុងស្មារតីផង។ សព្វថ្ងៃគ្មានគ្រីស្ដបរិស័ទណា ឬ នរណាម្នាក់ដឹងពីពេលដែលព្រះគ្រីស្ដយាងមកវិញទេ។ តាមអត្ថបទនេះព្រះគ្រីស្ដយាងមកវិញនៅពេលមួយដែលយើងមិនអាចដឹងបាន ប៉ុន្តែព្រះអង្គបានប្រទានមុខងារ ឲ្យយើងដែលជាអ្នកជឿបំពេញ គឺឲ្យបំពេញដោយការទទួលខុសត្រូវ និង ដោយប្រុងស្មារតី។ មុខងាររបស់យើង គឺយើងជាសាក្សីរបស់ព្រះគ្រីស្ដនៅក្នុងលោកនេះ គឺនៅក្នុងគ្រួសារនៅក្នុងសង្គមដោយបង្ហាញសេចក្ដីស្រឡាញ់ទាំងគិតគូដល់យុត្តិធម៌ និង សេរីភាពផង។

### សប្ដាហ៍ទី ២ ក្នុងរដូវអបអរសាទរព្រះគ្រីស្ដយាងមក

*ត្រូវនឹងថ្ងៃអាទិត្យ ទី ០៧ ខែធ្នូ ឆ្នាំ ២០១៤ (ម.ក ១, ១-៨)*

គម្ពីរម៉ាកុស បានចាប់ផ្ដើមឡើងដោយពាក្យថា "ដំណឹងល្អអំពីព្រះយេស៊ូគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់..."។ ដំណឹងល្អ គឺជាដំណឹងធ្វើឲ្យយើងសប្បាយចិត្ត គឺយើងសប្បាយចិត្តដោយសារ ព្រះជាម្ចាស់ប្រោសព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត ឲ្យទៅជាព្រះគ្រីស្ដយាងមកសង្គ្រោះមនុស្សលោកពីបាប... ។ នៅវាលរហោស្ថានលោកយ៉ូហានបានប្រកាសឲ្យអ្នកស្រុកប្រែចិត្តគំនិត គឺប្រែរបៀបរស់នៅ ដើម្បីទទួលព្រះគ្រីស្ដដែលយាងមក។ ក្នុងឱកាសរដូវអបអរសាទរព្រះគ្រីស្ដយាងមក ចូរយើងអង្វរព្រះជាម្ចាស់ ឲ្យយើងចេះរៀបចំខ្លួនឲ្យបានសមរម្យ ដើម្បីទទួលព្រះគ្រីស្ដដែលកំពុងតែយាងមកដល់ជារៀងរាល់ថ្ងៃ។

### សប្ដាហ៍ទី ៣ ក្នុងរដូវអបអរសាទរព្រះគ្រីស្ដយាងមក

*ត្រូវនឹងថ្ងៃអាទិត្យ ទី ១៤ ខែធ្នូ ឆ្នាំ ២០១៤ (យ.ហ ១, ៦-៨.១៩-*

ជនជាតិយូដាតែងរង់ចាំព្រះគ្រីស្ដយាងមក គេមិនដឹងច្បាស់ថានរណាជាព្រះគ្រីស្ដទេ ជាហេតុដែលអ្នកខ្លះសង្ស័យថា លោកយ៉ូហានជាព្រះគ្រីស្ដដែលត្រូវយាងមកតាម ព្រះបន្ទូលសន្យា។ លោកយ៉ូហាន ប្រកែកថារូបលោកមិនមែន ជាព្រះគ្រីស្ដទេ លោកធ្វើពិធីជ្រមុជទឹក ជូនប្រជាជនមែន ប៉ុន្តែលោកម្នាក់ដែលមកក្រោយនោះមានឋានៈខ្ពង់ខ្ពស់ណាស់ គឺលោកសំដៅទៅលើព្រះយេស៊ូ ។ យើងគ្រីស្ដបរិស័ទមិនស្រពិចស្រពិលទេ ព្រះសង្គ្រោះរបស់យើង គឺជាព្រះយេស៊ូ។ ក្នុងរដូវអបអរសាទរព្រះគ្រីស្ដយាងមកនេះ យើងសូមអង្វរព្រះជាម្ចាស់សូមព្រះអង្គបំភ្លឺឲ្យយើងមានជំនឿកាន់តែរឹងមាំឡើង លើព្រះយេស៊ូជាព្រះគ្រីស្ដ និង ជាព្រះអម្ចាស់របស់យើង។

### សប្ដាហ៍ទី ៤ ក្នុងរដូវអបអរសាទរព្រះគ្រីស្ដយាងមក

*ត្រូវនឹងថ្ងៃអាទិត្យ ទី ២១ ខែធ្នូ ឆ្នាំ ២០១៤ (ល.ក ១, ២៦-៣៨)*

ថ្ងៃនេះ ទេវទូតមកជូនដំណឹងអំពីកំណើតរបស់ព្រះយេស៊ូ ដល់នាងម៉ារី នៅពេលចុងក្រោយនាងម៉ារី ពោលទៅកាន់ទេវទូតថា៖ "នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមឲ្យសម្រេចតាមពាក្យរបស់លោកចុះ "ពាក្យនេះមានន័យថា នាងសុខចិត្តទទួលយកបេសកកម្មដ៏លំបាកនេះ ដោយទុកខ្លួនជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ នាងម៉ារីជាគម្រូរបស់អ្នកជឿគ្រប់ជំនាន់។ ក្នុងរដូវ អបអរសាទរព្រះគ្រីស្ដយាងមកនេះចូរយើងអង្វរព្រះជាម្ចាស់សូមឲ្យយើងមានចិត្តគំនិតដូចនាងម៉ារី ឲ្យយើងបន្ទាបខ្លួន ជាអ្នកបម្រើព្រះអង្គដោយបម្រើអ្នកដទៃ ជាពិសេស យកចិត្តទុកដាក់ ចំពោះអស់អ្នកដែលរងទុក្ខ វេទនាដោយសារជំងឺ ដោយសារភាពក្រីក្រ និង អស់អ្នកដែលត្រូវគេសង្កត់សង្កិន អ្នកដែលគេរឹបអូសដីធ្លីបណ្ដេញចេញពីផ្ទះ ពីភូមិ...

### សប្ដាហ៍ទី ៥ ក្នុងរដូវអបអរសាទរព្រះគ្រីស្ដយាងមក

*ត្រូវនឹងថ្ងៃអាទិត្យ ទី ២៨ ខែធ្នូ ឆ្នាំ ២០១៤ (ល.ក ២, ២២-៤០)*

ថ្ងៃនេះនៅព្រះវិហារ ក្រុងយេរូសាឡឹម លោកយ៉ូសែប និងនាងម៉ារីត្រូវទៅធ្វើពិធីជម្រះកាយ ឲ្យបានបរិសុទ្ធតាមធម្មវិន័យរបស់លោកម៉ូសេ ពេលនោះពួកគាត់ក៏នាំព្រះឱរសទៅថ្វាយព្រះជាម្ចាស់ដែរ។ លោកតាស៊ីម៉ូនជាមនុស្សសុចរិតម្នាក់ លោករង់ចាំព្រះគ្រីស្ដយាងមកយូរហើយ។ ពេលឃើញ ព្រះឱរសភ្លាម លោកប្រកាសថា "ព្រះឱរសនេះ ពិតជាពន្លឺដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ ស្គាល់ព្រះជាម្ចាស់..."។ សេចក្ដីនេះនាំឲ្យយើងនឹកទៅដល់ព្រះបន្ទូល របស់ព្រះយេស៊ូថាព្រះអង្គជាផ្លូវ គឺជាផ្លូវនាំមនុស្សលោកទៅព្រះបិតា ព្រះអង្គជាសេចក្ដីពិតគឺព្រះអង្គយាងមកពីព្រះជាម្ចាស់ជាព្រះបិតា ព្រះអង្គជាជីវិត គឺព្រះអង្គប្រទានអស់កល្បជានិច្ច ឲ្យមនុស្សលោកអាចរួមរស់ជា មួយព្រះបិតាបាន។ ចូរយើងអរព្រះគុណព្រះជាម្ចាស់ដែលប្រទានព្រះយេស៊ូមកចាប់កំណើតជាមនុស្ស ដើម្បីសង្គ្រោះមនុស្សលោកយើង៕

## កំណាព្យ ផ្ដល់តម្លៃដល់ជីវិតខ្លួនយើង

( បទពាក្យ៧ )

១- យើងមានជីវិតបិតគ្រប់ប្រាណ អន្ទោលឥតខានរាល់វេលា
មានវ័យក្មេងចាស់ផ្លាស់ជរា តាមជាប់គ្រប់គ្រាលើរូបកាយ ។
២- មានសព្វទុក្ខសោករោគសញ្ញា ចុកចាប់ឈឺផ្សាមានសប្បាយ
ខ្លះជួបទុក្ខភ័យក្ដីអន្តរាយ ទឹកចិត្តប្រែក្លាយអស់សង្ឃឹម ។
៣- បើមានឧបសគ្គស្ទាក់បំណង តាំងចិត្តកុំហ្មងឲ្យប៉ប្រិម
ជំនះឧបសគ្គចេញពីនឹម ប៉ុនប៉ងគ្រហឹមតាមយាយី ។
៤- រូបមួយចិត្តមួយជីវិតមួយ ត្រូវតែលើកស្ទួយគ្រងអច្ចលី
តម្កើងឲ្យខ្ពស់ព្រោះជីវី ជីវិតគ្មានពីរមានតែមួយ ។
៥- យើងយុវជនកុំគិតខ្លី រឿងតូចធំក្ដីកុំភ័យព្រួយ
តស៊ូយកឈ្នះព្រះអង្គជួយ រក្សាស្លឹកត្រួយជីវិតអ្នក ។
៦- កុំខ្លាចរុញរាឬដកថយ បើមានថ្ងៃក្រោយជួបឧបសគ្គ
ត្រូវឈានទៅមុខកុំបីអាក់ ប្រឹងដោយជឿជាក់ជំហរខ្លួន ។
៧- យើងគិតឲ្យវែងស្វែងហើយយល់ តាំងចិត្តគិតដល់យ៉ាងមាំមួន
កុំឲ្យបញ្ហាជាន់ផ្ទួនៗ ដោះស្រាយចាប់ជួនចិត្តត្រជាក់ ។

បណ្ដាយព្រាប,
និពន្ធដោយៈ អ្នកស្រី ខុជ ណារី,
មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និងសុខភាព
នៃអភិវឌ្ឍជនបទអង្គ័ស្នួល / JSC

# រូបភាពសកម្មភាពព្រះសហគមន៍ទាំងបីភូមិភាគ











ព្រះសង្ឃនិងបូជាចារ្យកាតូលិកនិមន្ត និងអញ្ជើញចូលរួមក្នុងពិធីតែងតាំង លោក មួង រស់ជាបូជាចារ្យកាតូលិកនៅបាត់ដំបង ។



បុណ្យគោរពសន្ត ហ្វ្រង់ស្វ័រសាវីយេ នៅព្រះសហគមន៍កាតូលិកចំប៉ា ។



បុណ្យរំលឹកខួប២ឆ្នាំដែលស្រង់ព្រះនាងម៉ារីចេញពីទឹក ។



បងស្រី បេទី ធ្វើពាក្យសន្យាក្នុងក្រុមសហប្រតិបត្តិការពីកេបិក កាលពីថ្ងៃ ទី៣ ខែធ្នូកន្លងទៅ។

---

អេម៉ាណូអែល
"សម្លេងពីព្រះសហគមន៍កាតូលិក"

| | |
|---|---|
| ភ្នំពេញ | : **FM 104 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : **FM 91.0 Mhz** ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ |
| សៀមរាប | : **FM 107.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ធំ | : **FM 103.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ចាម | : **FM 100.5 Mhz** ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : **FM 92.5 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពត | : **FM 93.25 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

កម្មវិធីវិទ្យុ

" ខ្ញុំត្រូវការអ្នក "

ជាកម្មវិធីសម្រាប់យុវជន

ផ្សាយតាមរលកធាតុអាកាស FM99.5Mhz
រាល់ថ្ងៃអង្គារ៍
វេលាម៉ោង ១០:០០ - ១១:០០ព្រឹក